# អានិសង្សកថា

## សម្រាប់ធម្មកថិក

និពន្ធបណ្ឌិត

**ឃិន-ចន់**

ការផ្សាយរបស់

តូប ៧២ , ៧៣ ផ្សារអូរឫស្សី

ព.ស ២៥៤៨ គ.ស២០០៤

ផ្សាយចេញពី

www.haotrai.com

ចែកជាឈ្មួញឆានដោយ

# អារម្ភកថា

ដោយយល់ឃើញថា ព្រះករុណាគ្រប់ព្រះអង្គដែលជាធម្មកថិកថ្មី មានការសង្ស័យរឿងឆ្ងល់ជាច្រើនអង្គក្នុងអានិសង្សនៃបុណ្យមួយៗ ព្រោះកម្រនឹងជួបប្រទះឱ្យបានសព្វគ្រប់ណាស់ បើបានសិក្សាខ្លះៗ មកហើយ ក៏នៅតែមិនគ្រប់គ្រាន់ ដ្បិតមាននៅតែតម្រាផ្សេងៗ ពីគ្នា ជាហេតុនាំឱ្យលំបាកក្នុងការស្រាវជ្រាវ ។

ហើយម្យ៉ាងទៀត បើមានខ្លះមកហើយក៏ដោយក៏នៅតែពុំទាន់បំណងនៃការសិក្សានៅឡើយ ។

ព្រោះបើមានធម្មាធិដ្ឋាន ខ្វះបុគ្គលាធិដ្ឋាន. មានបុគ្គលាធិដ្ឋាន ខ្វះធម្មាធិដ្ឋាន ។

ចំណែកអានិសង្សកថានេះ មានទាំងពីរចំណែកគឺ ធម្មាធិដ្ឋាន និងបុគ្គលាធិដ្ឋានភ្ជាប់ជាមួយគ្រប់ៗ អានិសង្សទាំងអស់ វៀរលែងតែកន្លែងខ្លះដែលមានន័យស្រដៀងគ្នានឹងខាងដើមស្រាប់នោះ មិនបាច់ដាក់មកទេ ព្រោះនាំឱ្យមានទំព័រច្រើនពេកម្យ៉ាង. ម្យ៉ាងទៀត វាជាការសាំដដែលៗ ទៅវិញ ។

សៀវភៅនេះកើតឡើង មិនមែនគ្រាន់តែបណ្តាហេតុដូចខាងលើនេះប៉ុណ្ណោះទេ. ជាពិសេសព្រះករុណាគ្រប់ព្រះអង្គដែលគង់សិក្សាធម្មវិន័យ វត្តនរាធិបតី ស្រុកសង្កែ-បាត់ដំបងជាដើម លោកមានពុទ្ធដីកាជូនលើកចំណុចនេះទៀតថា ទោះបីរវល់យ៉ាងណាក៏ដោយក៏ត្រូវតែឆ្លៀត ឱកាសរៀបរៀង

សៀវភៅអានិសង្សកថានេះឱ្យខាងតែបាន ព្រោះវាជាការងាយដល់កុលបុត្រអ្នកត្រូវការសិក្សា ។

ហើយជាចាំបាច់បំផុត ដល់ធម្មកថិកថ្មីដែលត្រូវការទេសនា-អាកាត់សេចក្ដីអ្វីមួយដែលជាប់ទាក់ទងផ្លូវលោក-ផ្លូវធម៌ តាមទ្រឹស្ដីពុទ្ធនិយម-ខេមរនិយម ។

ព្រះពុទ្ធដីកាព្រះករុណាគ្រប់ព្រះអង្គ ដែលផ្ដុយចេញពីព្រះឱស្ឋចុងក្រោយនេះស័ក្ដិសិទ្ធិណាស់ ហាក់ដូចជាកូនសរទិព្វមួយបោលទម្លុះបេះដូងខ្ញុំព្រះករុណា ឱ្យអត់ទ្រាំពុំបាន ខានពុំកើត ក៏លៃលកឆ្លៀតឱកាសពីការនិពន្ធសៀវភៅផ្សេងៗ មានអលង្ការដ្ឋ-កិច្ចសំខាន់ដែលពលរដ្ឋឯករាជ្យត្រូវដឹង-និងសៀវភៅបកិណ្ណកធម៌ពិសេសជាដើម មកខំស្រាវជ្រាវក្បួនខ្នាតដទៃ និងតាមការចេះចាំមកពីដើមខ្លះ ចងក្រងឡើងជាសៀវភៅ "អានិសង្សកថា" ដែលព្រះករុណាកំពុងអាននៅព្រះហស្ដនេះឯង ។

សៀវភៅនេះទោះបីជាយ៉ាងណា ក៏ខ្ញុំព្រះករុណាមានសេចក្ដីសង្ឃឹមយ៉ាងមាំថា នឹងបានជានាវាដ៏តូចមួយសម្រាប់ព្រះករុណាគ្រប់ព្រះអង្គឆ្លងផុតពីអន្លង់នៃការសង្ស័យ-ងឿងឆ្ងល់ពុំខានឡើយ. ជាអន្លង់ដែលខ្ញុំព្រះករុណាធ្លាប់បានហែលឆ្លងរួចមកហើយ ។

**ខាងឆី** បញ្ចប់ ខ្ញុំព្រះករុណាសូមនិមន្តព្រះតេជះគុណ អស់លោកទាំងឡាយ ដែលពោរពេញទៅដោយបច្ចេកទេសខាង "អត្ថគម្ពីរភាព" មេត្តាចារបំពេញនូវបន្ទាត់ណាដែលឃ្លាតចាក សំយោគព្យញ្ជនៈ អក្ខរាវិរុទ្ធ វោទវត្ត

ល្បះ ឃ្លា ភាសាបាលីសេចក្ដីសម្រាយនោះឱ្យទាន ដើម្បីឱ្យបានជាតម្រាមួយដ៏ល្អ សមតាមបំណងនៃសិក្ខាកាមកុលបុត្រទាំងឡាយសម្រាប់សិក្សាបណ្ដុះនិស្ស័យ សតិ បញ្ញា ស្មារតី. តទៅ ។

******

ដោយវិរិយភាពដែលបានខិតខំទ្រាំអង្គុយបង្ហូរទឹកខ្មៅនៅលើក្រដាសនេះ គឺជាបុញ្ញលាភមួយដ៏វិសេស. សូមជូន-ប្រគេនចំពោះបុព្វការីជនទាំងឡាយ មានមាតា-បិតា និងគ្រូឧបជ្ឈាយ៍អនុស្សាវរីយ៍ណ្ណជាដើម សូមលោកទាំងនោះប្រកបដោយនិរទុក្ខ-និរភ័យ មានព្រះជន្មវស្សាទីឃាយុយឺនយូរដរាបដល់រយព្រះវស្សា ។

**សូមសាកលលោកសន្តិភាព!**

សូមសាសនាព្រះសម្ពុទ្ធប្រតិស្ឋាននៅអស់កាលដ៏យូរ !

និពន្ធបណ្ឌិត

**យិន-ចន់**

# មាតិកាធម៌


**លេខរៀង** **ទំព័រ**

(១-) ទានមានឋានៈផ្សេងៗគ្នា ------------------------- ១

២- អានិសង្សរបស់បុគ្គលអ្នកមានសទ្ធា ៥ យ៉ាង -------------- ២

៣- សម្បត្តិរបស់ជនអ្នកមានសទ្ធាមិនដែលវិនាសសាបសូន្យ

ជាបុគ្គលាធិដ្ឋាន ----------------------------- ២

៤- ទានបានមគ្គ ៣ យ៉ាង ------------------------ ៤

៥- អានិសង្សទាន-បុគ្គលាធិដ្ឋាន --------------------- ៤

៦- អានិសង្សអាមិសទាន ៥ យ៉ាង -------------------- ៩

៧- អានិសង្សអាមិសទាន-បុគ្គលាធិដ្ឋាន ----------------- ១០

៨- សម្បទាធម្មជាតិធ្វើទានឱ្យមានផល ៣ យ៉ាង ------------ ១៤

៩- ទានដែលមានផលានិសង្សច្រើន ------------------ ១៥

១០-) សីលសម្បត្យានិសង្សកថា --------------------- ១៦

១១- អានិសង្សសីល ៥ -------------------------- ១៧

១២- អានិសង្សសីល-បុគ្គលាធិដ្ឋាន ------------------- ២០

១៣- អានិសង្សអ្នកសំដែងធម៌ ៥ យ៉ាង ------------------ ២២

១៤- ឧបនិស្ស័យការស្ដាប់ធម៌ ៤ យ៉ាងទៀត --------------- ២៣

១៥- ផលនៃការស្ដាប់ធម៌ ៤ យ៉ាង -------------------- ២៣

១៦- អានិសង្សអ្នកស្ដាប់ធម៌ ៥ យ៉ាង ------------------ ២៤

១៧- អានិសង្សនៃការស្តាប់ធម៌-បុគ្គលាធិដ្ឋាន ---------------- ២៤
១៨- អានិសង្សបុណ្យ ៥ យ៉ាង ------------------------- ២៨
១៩- អានិសង្សបុណ្យជាបុគ្គលាធិដ្ឋាន ------------------- ២៨
(២០) អានិសង្សកឋិន ៥ យ៉ាង របស់ភិក្ខុ ------------------ ៣៤
២១- កឋិនទាន --------------------------------- ៣៥
២២- កឋិនទានានិសង្សកថា ------------------------- ៣៨
២៣- អានិសង្សខន្តី ៥ យ៉ាង ------------------------- ៣៩
២៤- អានិសង្សខន្តីបុគ្គលាធិដ្ឋាន --------------------- ៤០
(២៥) អានិសង្សកតញ្ញូ ៤ យ៉ាង ------------------------ ៤២
២៦- អានិសង្សកតញ្ញូបុគ្គលាធិដ្ឋាន -------------------- ៤២
២៧- អានិសង្សមេត្តា ១១ យ៉ាង ---------------------- ៤៤
២៨- អានិសង្សមេត្តា-បុគ្គលាធិដ្ឋាន ------------------- ៤៦
២៩- អានិសង្សសមាធិភាវនា ៥ យ៉ាង ------------------- ៥២
៣០- ភាវនាបានសម្រេចផល ៣ យ៉ាង ------------------- ៥៤
៣១- អានិសង្សចំរើនភាវនា-បុគ្គលាធិដ្ឋាន ---------------- ៥៤
(៣២) ធុតង្គកថា ---------------------------------- ៥៦
៣៣- អានិសង្សក្នុងបំសុកូលិកង្គ ១២ យ៉ាង --------------- ៥៨
៣៤- អានិសង្សក្នុងតេចីវរិកង្គ ១១ យ៉ាង ---------------- ៦០
៣៥- អានិសង្សក្នុងបិណ្ឌបាតិកង្គ ១៥ យ៉ាង --------------- ៦១

៣៦- អានិសង្សក្នុងសបទានចារិកង្គ ៨ យ៉ាង ---------------- ៦៣

៣៧- អានិសង្សក្នុងឯកាសនិកង្គ ៨ យ៉ាង ------------------ ៦៤

៣៨- អានិសង្សក្នុងបត្តបិណ្ឌិកង្គ ៦ យ៉ាង ----------------- ៦៤

៣៩- អានិសង្សក្នុងខលុបច្ឆាភត្តិកង្គ ៥ យ៉ាង ---------------- ៦៥

៤០- អានិសង្សក្នុងអារញ្ញិកង្គ ៨ យ៉ាង ------------------ ៦៦

៤១- អានិសង្សក្នុងរុក្ខមូលិកង្គ ៦ យ៉ាង ------------------ ៦៧

៤២- អានិសង្សក្នុងអព្ភោកាសិកង្គ ៥ យ៉ាង ---------------- ៦៨

៤៣- អានិសង្សក្នុងសោសានិកង្គ ១០ យ៉ាង ---------------- ៦៨

៤៤- អានិសង្សក្នុងយថាសន្ថតិកង្គ ៦ យ៉ាង ---------------- ៧០

៤៥- អានិសង្សក្នុងនេសជ្ជិកង្គ ៥ យ៉ាង ------------------ ៧១

៤៦- អានិសង្សបញ្ញា ៤ យ៉ាង ----------------------- ៧២

៤៧- អានិសង្សបញ្ញា បុគ្គលាធិដ្ឋាន -------------------- ៧២

*******

# ទានមានឋានៈផ្សេងគ្នា

◆◆◆◆◆◆◆◆◆◆

ទាយកឱ្យទានដល់បដិគ្គាហកៈ ថ្នាក់ជាន់ទាបនិងថ្នាក់ជាន់ខ្ពស់ ដែលមិនមានគុណវិសេស និងមានគុណវិសេស តិចច្រើនជាងគ្នានោះមានអំណោយនៃអានិសង្សផ្សេងគ្នាយ៉ាងនេះគឺៈ

ឱ្យទានដល់សត្វតិរច្ឆាន បានអានិសង្សមួយរយជាតិ. ឱ្យទានដល់មនុស្សបុថុជ្ជនទ្រុស្តសីល បានអានិសង្សមួយពាន់ជាតិ, ឱ្យទានដល់មនុស្សបុថុជ្ជនមានសីល បានអានិសង្សមួយពាន់ជាតិ. ឱ្យទានដល់បុគ្គល (តាបស) ខាងក្រៅពុទ្ធសាសនាដែលមានសេចក្តីនឿយណាយក្នុងកាម បានអានិសង្សមួយសែនកោដិជាតិ.ឱ្យទានដល់បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល(១) បានអានិសង្សរាប់ពុំបានប្រមាណពុំអស់ឡើយ ។ ចំណែកខាងសោតាបន្នបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកិទាគាមិផលក្តី សកិទា-គាមិបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផលក្តី អនាគាមិបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផលក្តី ព្រះអរហន្តជាសាវករបស់ព្រះតថាគតក្តី ព្រះបច្ចេកសម្ពុទ្ធក្តី ព្រះតថាគត ជាព្រះអរហន្តសម្មាសម្ពុទ្ធក្តី មិនបាច់និយាយ គឺថាមានអានិសង្ស ច្រើនលើស

---

(១) សូម្បីឧបាសកដល់ត្រឹមតែសរណគមន៍ ៣ ក្តី កាន់សីល ៥ ក្តី សីល ១០ ក្តី សាមណេរ ឬ ភិក្ខុទើបនឹងបួសបានមួយថ្ងៃក្តី ភិក្ខុមានវត្តប្រតិបត្តិយូរហើយក្តី ភិក្ខុទ្រទ្រង់វិបស្សនាក្តី ទាំងអស់នេះ ឈ្មោះថាប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ។

ប្រមាណនឹងរាប់ថាចំនួនប៉ុណ្ណេះប៉ុណ្ណោះពុំបានឡើយ ។

## អានិសង្សរបស់បុគ្គលអ្នកមានសទ្ធា ៥ យ៉ាងគឺៈ

១. **បឋមំ អនុកម្បន្តិ** កុលបុត្រអ្នកមានសទ្ធា ព្រះតថាគតតែងអនុគ្រោះមុនគេ.

២. **បឋមំ ឧបសំកម្បន្តិ** កុលបុត្រអ្នកមានសទ្ធា ព្រះជាម្ចាស់ចូលទៅជិតមុនគេ.

៣. **បឋមំ បដិគណ្ហន្តិ** កុលបុត្រអ្នកមានសទ្ធា ព្រះជាម្ចាស់ចូលទៅទទួលទានមុនគេ.

៤. **បឋមំ ធម្មះទេសនំ** កុលបុត្រអ្នកមានសទ្ធា ព្រះជាម្ចាស់សំដែងឱ្យស្តាប់មុនគេ.

៥. **សគ្គលោកំ ឧបបជ្ជតិ** កុលបុត្រអ្នកមានសទ្ធា រមែងទៅកើតក្នុងទេវលោកគឺស្ថានសួគ៌ ។

## សម្បត្តិរបស់ជនមានសទ្ធាមិនដែលវិនាស
## សាបសូន្យ ជាបុគ្គលាធិដ្ឋាន
## រឿងព្រាហ្មណ៍សម្លាប់កូនធ្វើទាន

កាលពីព្រេងនាយ មានព្រាហ្មណ៍ម្នាក់មានសទ្ធាជឿស៊ប់ក្នុងព្រះពុទ្ធ

សាសនា ជាអ្នកពេញចិត្តក្នុងការធ្វើទាន ។ ព្រាហ្មណ៍នេះកាលមាតាបិតារៀប ឱ្យមានគូស្រករ បានចែកទ្រព្យសម្បត្តិជាច្រើនស្មើភាគនឹងបងប្អូនរបស់គាត់ ដល់ពេលក្រោយមកព្រាហ្មណ៍នេះទៅជាអ្នកក្រដើរសុំទានគេ ឯបងប្អូនទាំងប៉ុន្មានសុទ្ធតែជាអ្នកមានទ្រព្យ ប៉ុន្តែគេមិនដែលឱ្យវត្ថុអ្វីបន្តិចបន្តួចដល់ព្រាហ្មណ៍នោះឡើយ. ពួកជនទាំងឡាយតែងហៅព្រាហ្មណ៍នោះថា ទុគ្គត-ព្រាហ្មណ៍ ។

ឯទុគ្គតព្រាហ្មណ៍នោះ មានកូនប្រុសមួយរូប ជាទីស្រឡាញ់ពេញចិត្តនៃឪពុកមានិងម្ដាយមីងក្រៃពេក ។ ថ្ងៃមួយមានព្រះអរហន្តមួយអង្គនិមន្តទៅបិណ្ឌបាត ទុគ្គតព្រាហ្មណ៍ឃើញហើយមានសេចក្ដីជ្រះថ្លានិមន្តចូលទៅផ្ទះដើម្បីទទួលភត្ត លុះលោកចូលទៅគង់ហើយ ទូលលោកឱ្យរង់ចាំបន្តិច ទើបគិតគ្នាប្ដីប្រពន្ធថា យើងបានអ្វីធ្វើចង្ហាន់បើក្នុងផ្ទះយើងសូម្បីតែអង្ករ ១ គ្រាប់ក៏គ្មានផង ទុគ្គតព្រាហ្មណ៍នឹកឃើញថា បងប្អូនយើងស្រឡាញ់កូនយើងណាស់ បើយើងយកកូនទៅដាក់នៅមាត់រូងនាគរាជក្រោយផ្ទះយើង នាគនឹងខាំស៊ីមួយរំពេច ហើយយើងទៅប្រាប់បងប្អូនថា កូនស្លាប់ឥឡូវបាននិមន្តលោក ១ អង្គមកធ្វើបុណ្យឱ្យវា ។ បងប្អូនយើងមុខតែយកអង្ករត្រីជាដើមមកឱ្យធ្វើចង្ហាន់លោកមិនខាន. លុះគិតហើយក៏យកកូនទៅដាក់មាត់រន្ធនាគរាជតូនចាំមើល ។ នាគរាជកាលបើធុំក្លិនមនុស្សហើយក៏ស្ទុះចេញមក ។

ដោយគុណនៃសទ្ធាពិតប្រាកដរបស់ព្រាហ្មណ៍និងអានុភាពនៃអាយុរបស់កុមារនោះមិនអស់ផង ក៏បណ្ដាលឱ្យនាគរាជនោះភ្ញាក់ផ្អើលនឹងកុមារស្ទុះរត់

ចេញទៅ ជ្រុះកែវពីក្នុងមាត់ក្បែររន្ធ ។ កុមារឃើញកែវភ្លឺៗ រើសយកមកកាន់លេង ។ ឯមាតាបិតាឃើញកាន់កែវដូច្នោះ ក៏ស្ទុះទៅយក កូននិងកែវមក. កែវនោះល្អក្រៃលែងរកកាត់ថ្លៃមិនបាន យកទៅលក់ឱ្យសេដ្ឋីក្នុងនគរនោះ គេមិនហ៊ានទិញព្រោះគ្មានលុយឱ្យ.ទុគ្គតព្រាហ្មណ៍ក៏បញ្ចាំកែវទុកនឹងសេដ្ឋីសិនសុំយកម្ហូបចំណី-ចាយសម្ងួមកប្រគេនលោក ។ ដល់ពេលក្រោយបានយកកែវទៅថ្វាយព្រះរាជាៗ ទ្រង់តាំងឱ្យធ្វើជាសេដ្ឋីក្នុងនគរនោះ. ដល់អស់អាយុបានទៅកើតស្ថានសួគ៌ទៀត ។

រឿងនេះបំភ្លឺឱ្យឃើញថា សទ្ធាបើមានពិតប្រាកដមាំមួនចំពោះបុគ្គលណាហើយ អាចរក្សានូវទ្រព្យសម្បត្តិដែលបំរុងនឹងវិនាសមិនឱ្យវិនាស ហើយញ៉ាំងប្រយោជន៍ដែលជននោះប្រាថ្នាឱ្យសម្រេចបានដូចបំណង សមដូចពុទ្ធភាសិតថា:

**"សទ្ធា សាធុបតិដ្ឋិតា"** សទ្ធាដែលបុគ្គលបានតម្កល់ស៊ប់ហើយអាច ញ៉ាំងប្រយោជន៍ឱ្យសម្រេចបាន ។

## ទានបានមគ្គ ៣ យ៉ាង គឺ:

១- សោតាបត្តិមគ្គ. ២- សកិទាគាមិមគ្គ. ៣- អនាគាមិមគ្គ ។

## អានិសង្សទាន_ជាបុគ្គលាធិដ្ឋាន

## រឿងសុខសាមណេរ

## កាលកើតជា "គន្ធគតិកបុរស"

សេចក្តីថា កាលកន្លងទៅហើយ មានកូនសេដ្ឋីក្នុងក្រុងពារាណសីម្នាក់ ឈ្មោះ គន្ធកុមារ ។

កាលបិតាធ្វើមរណកាលទៅ ព្រះរាជាទ្រង់ព្រះរាជទាននាទីជាសេដ្ឋី ដល់កុមារនោះ ។ លំដាប់នោះនាយឃ្លាំងបានបើកទ្វារឃ្លាំង បង្ហាញទ្រព្យដល់គន្ធសេដ្ឋីនោះថា: បពិត្រលោក! ទ្រព្យប៉ុណ្ណេះជារបស់បិតាលោក. ប៉ុណ្ណេះជារបស់ជីតាលោក ។ សេដ្ឋីរមិលមើលគំនរទ្រព្យហើយពោលថា: "ម្ដេចក៏ជីតានិងបិតាអញមិនជញ្ជូនយកទ្រព្យទាំងនេះទៅជាមួយផង? ជនទាំងអស់នោះទុកទ្រព្យឱ្យនៅ ហើយទៅដៃទទេ នេះព្រោះតែខ្លួនមនុស្សពាល". "ឯអញនឹងស៊ីទ្រព្យទាំងនេះឱ្យអស់ហើយសឹមទៅ" ទើបគាត់ចំណាយទ្រព្យ ១ សែនកហាបណៈ ឱ្យជាងចាត់ចែងធ្វើបន្ទប់ទឹករចនាដោយកែវផលិក. ចំណាយ ១ សែនកហាបណៈឱ្យធ្វើផែនក្ដារសម្រាប់ងូតទឹក ក៏រចនាដោយកែវផលិកដែរ. ចំណាយ ១ សែនកហាបណៈ ឱ្យធ្វើបល្ល័ង្កសម្រាប់អង្គុយ. ចំណាយ ១ សែនកហាបណៈ ឱ្យធ្វើភាជន. ចំណាយ ១ សែនកហាបណៈឱ្យធ្វើមណ្ឌបត្រង់កន្លែងបរិភោគភោជនាហារ. ហើយឱ្យ ១ ពាន់កហាបណៈជាថ្លៃភោជនក្នុងវេលាព្រឹក. ១ ពាន់កហាបណៈក្នុងវេលាល្ងាច. បើក្នុងថ្ងៃពេញបូណ៌មី គាត់ចំណាយ ១ សែនកហាបណៈសម្រាប់ភោជន. ចំណាយ ១ សែនកហាបណៈសម្រាប់គាត់តែងនគរ. ហើយឱ្យទូងភេរីប្រាប់មហាជនឱ្យមកមើលគាត់បរិភោគ ។ សម័យខាងក្រោយមក មានមនុស្សអ្នកស្រុកក្រៅម្នាក់ មកសំណាក់នៅផ្ទះសំឡាញ់ម្នាក់ក្នុងក្រុងនោះ ។

ជូនជាថ្ងៃនោះត្រូវលើថ្ងៃពេញបូណ៌មី. ក៏បុរសសំឡាញ់ បបួលទៅមើលគន្ធសេដ្ឋីបរិភោគ ។ ឯគាមវាសី (បុរសអ្នកនៅស្រុកក្រៅ) បានទៅដល់បានឃើញសិរីវិលាសដ៏អស្ចារ្យ បានធុំក្លិនបណីតាហារ ក៏អត់ទ្រាំពុំបាន. ទើបស្រែកយ៉ាងខ្លាំងបីដងថា: បពិត្រលោកសេដ្ឋី! ខ្ញុំប្របាទក្រាបប្រណិបតន៍ ។ គន្ធសេដ្ឋីសួរថា: នរណាហ្នឹង ? អ្នកឯងមកពីណា? មានការអ្វី? គាមវាសីឆ្លើយថា ខ្ញុំប្របាទ លោក. ខ្ញុំប្របាទមកពីស្រុកក្រៅ. មានសេចក្ដីស្រេកឃ្លានចង់ទទួលទានភត្តក្នុងភាជនៈរបស់លោកនេះណាស់. សូមលោកឱ្យទាន ១ ដុំមក ។ សេដ្ឋីថា អញមិនអាចឱ្យឯងបានទេ ។ ឱលោកម្ចាស់អើយ ! ខ្ញុំប្របាទបើមិនបានទទួលទានបាយនេះ មុខជាស្លាប់ឥឡូវនេះមិនខាន ។

អើ បើដូច្នោះ ចូរអ្នកឯងធ្វើការក្នុងផ្ទះអញ ៣ ឆ្នាំចុះ, អញនឹងឱ្យភត្ត ១ ភាជនដល់អ្នកឯង ។ បុរសនោះ ក៏លះបង់ប្រពន្ធ-កូន ហើយចូលមកធ្វើការឈ្នួលអស់ ៣ ឆ្នាំ ដើម្បីយកភត្ត ១ ភាជន ។

ទើបគេហៅគាត់ថា: "ភត្តភតិកបុរស" ដូច្នេះជាប់តមក ។ លុះដល់កំណត់ថ្ងៃគំរប់៣ឆ្នាំ ក៏ពួកអ្នកចាត់ចែងភត្តទៅជំរាបសេដ្ឋី ។ ទើបសេដ្ឋីឱ្យនាយឃ្លាំងចំណាយប្រាក់ ៣ ពាន់កហាបណៈដើម្បីបុរសនោះ គឺ ២ ពាន់កហាបណៈសម្រាប់ភោជនក្នុងវេលាល្ងាច. ១ ពាន់កហាបណៈសម្រាប់ភោជនក្នុងវេលាព្រឹក. ហើយនិយាយថា: "ថ្ងៃនេះ ចូរអ្នកទាំងឡាយធ្វើគ្រឿងប្រដាប់សម្រាប់អញ ឱ្យជាគ្រឿងប្រដាប់សម្រាប់អ្នកនោះវិញចុះ" លុះនិយាយដូច្នោះហើយ ក៏ឱ្យពួកបរិវារចោមគាល់បំរើបុរសនោះ លើកលែងតែនាងចិន្តាមណី ដែលជា

ភរិយាសំណាប់ម្នាក់ចេញ ។ បុរសនោះ ក៏អង្គុយលើផែនក្តារក្នុងបន្ទប់សម្រាប់ងូតទឹករបស់សេដ្ឋី ស្លៀកសំពត់របស់សេដ្ឋី. អង្គុយលើបល្ល័ង្ករបស់សេដ្ឋីនោះ ។ ទើបសេដ្ឋីឱ្យទូងភេរីឃោសនាប្រាប់អ្នកនគរថា ភត្តភតិកបុរស ធ្វើការឈ្នួលអស់ ៣ ឆ្នាំ ក្នុងផ្ទះគន្ធសេដ្ឋី. ឥឡូវបានបរិភោគភត្តសំរាប់សេដ្ឋី ចូរមហាជនប្រុសស្រី មកមើលការបរិភោគរបស់បុរសនោះចុះ ។ មហាជនក៏ឡើងលើមញ្ចាមើលបុរសនោះស្ទើរកក្រើកផែនប្រឹថពី ។ ពួកស្រីរបាំក៏ចោមរោមជាបរិវារ ពួកអ្នកចាត់ចែងភោជនាហារ ក៏ លើកភត្តមកតម្កល់ទុកពីខាងមុខបុរសនោះ ។

កាលនោះ មានព្រះបច្ចេកពុទ្ធ ១ អង្គ គង់ចូលសមាបត្តិអស់ ៧ ថ្ងៃនៅលើភ្នំគន្ធមាទន៍. លុះចេញអំពីសមាបត្តិ ក៏ពិចារណារកភិក្ខាចារដ្ឋាន បានជ្រាបថា "បុរសនេះអាចធ្វើនូវសេចក្តីសង្គ្រោះដល់លោកផង នឹងបានមហាសម្បត្តិព្រោះអាស្រ័យសេចក្តីសង្គ្រោះនេះផង" ហើយក៏ឃ្លុំចីវរស្ពាយបាត្រហោះមកតាមអាកាស ចូលមកតាមចន្លោះបរិវារ បង្ហាញខ្លួនក្នុងទីចំពោះមុខបុរសនោះ ។

បុរសនោះ ឃើញព្រះបច្ចេកពុទ្ធហើយ ក៏គិតថា: អញខំធ្វើការឈ្នួលអស់ ៣ ឆ្នាំទើបបានភត្ត ១ ភាជន ក៏ព្រោះតែខ្លួនមិនបានឱ្យទានពីជាតិមុនមកតើ. ឯភត្តរបស់អញនេះ រក្សាជីវិតអញបានត្រឹមតែមួយថ្ងៃមួយយប់ប៉ុណ្ណឹងទេ. បើអញថ្វាយភត្តនេះដល់លោកម្ចាស់ ផលទាននេះនឹងរក្សាអញអស់ ១ សែនកោដិកប្ប ។

ទើបបុរសនោះ ឥតដាក់បាយក្នុងមាត់សូម្បី ១ ដុំឡើយ. ខំបន្ទោបង់ចំណង់ហើយ លើកភាជនភត្តប្រទូលឡើងដាក់ភត្តក្នុងបាត្រព្រះបច្ចេកពុទ្ធ

ហើយធ្វើសេចក្តីប្រាថ្នាថា: បពិត្រព្រះអង្គដ៏ចំរើន. ខ្ញុំធ្វើការឈ្នួលអស់ ៣ ឆ្នាំ ព្រោះតែចង់បានភត្ត ១ ភាជននេះ. ខ្ញុំមានសេចក្តីលំបាកខ្លាំងណាស់. តទៅខ្ញុំសូមឱ្យបានសេចក្តីសុខគ្រប់ៗ កន្លែងដែលខ្ញុំកើត ហើយខ្ញុំសូមឱ្យបានសម្រេចធម៌ដូចព្រះអង្គផង ។ ព្រះបច្ចេកពុទ្ធធ្វើអនុមោទនាហើយ ក៏ហោះទៅភ្នំគន្ធមាទន៍វិញ ។ ពួកមហាជន ក៏បានឃើញលោក ដរាបតែលោកទៅដល់ភ្នំនោះ. ឃើញលោកចែកចង្ហាន់បិណ្ឌបាត្រនោះជា ៥០០ ចំណែក ប្រគេនព្រះបច្ចេកពុទ្ធទាំង ៥០០ អង្គឆាន់គ្រប់គ្រាន់. ទើបពួកមហាជនស្រែកឱ្យសព្ទ-សាធុការពរខ្សៀវខ្សាស្ទើរកក្រើកផែនដី ។ ឯគន្ធសេដ្ឋី មានសេចក្តីជ្រះថ្លា ក៏ឱ្យប្រាក់ ១ ពាន់កហាបណៈ សូមចែកចំណែកបុណ្យពីបុរសនោះ ហើយបែងភោគសម្បត្តិខ្លួនពាក់កណ្តាលចែកឱ្យបុរសនោះទៀត ។

ថ្ងៃក្រោយមក ព្រះរាជាបានជ្រាបរឿងនោះ ក៏ទ្រង់ព្រះរាជទានប្រាក់ ១ ពាន់កហាបណៈ សូមចែកចំណែកបុណ្យពីបុរសនោះ ហើយទ្រង់តាំងនាទីឱ្យជាមហាសេដ្ឋី នឹងឱ្យសំឡាញ់និងគន្ធសេដ្ឋីនោះផង ។

សេដ្ឋីថ្មីនោះ បានឈ្មោះថា ភត្តភតិកសេដ្ឋី ។ លុះភត្តភតិកសេដ្ឋីនោះលែងជាតិអំពីទីនេះទៅ បានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិអស់ ១ ពុទ្ធន្តរ ក៏ច្យុតមកកើតក្នុងត្រកូលជាឧបដ្ឋាកនៃព្រះសារីបុត្តត្ថេរ នៅនគរសាវត្ថីក្នុងសម័យពុទ្ធុប្បាទនេះ ។

✦✦✦✦✦

# អានិសង្សអាមិសទាន ៥ យ៉ាងគឺ:

១- **បិយោ ហោតិ មនាបោ** អ្នកឱ្យទាន រមែងជាទីស្រឡាញ់ពេញចិត្តនៃអ្នកផងច្រើនគ្នា ដែលនៅជិតខាង ឬនៅក្នុងទីឆ្ងាយ.

២- **សប្បុរិសា ភជន្តិ** ពួកសប្បុរស រមែងរាប់រកសង្គ្រោះនូវបុគ្គលដែលមានសទ្ធាធ្វើទាន ដោយការស្វែងរកប្រយោជន៍និងប្រាថ្នាចង់ឱ្យបុគ្គលអ្នកឱ្យទាននោះ បានសេចក្តីសុខ-ចំរើនគ្រប់កាល.

៣- **កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិសព្ទដ៏ពីរោះ រមែងខ្ទរខ្ទាយសុះសាយទៅក្នុងទិសទាំងពួង ទាំងមនុស្សនិងទេវតា ក៏រមែងឱ្យសព្ទ-សាធុការ.

៤- **វិសារទោ ឧបសង្កមតិ** អ្នកឱ្យទាន ទោះចូលទៅកាន់ចំណោមបរិស័ទណាមួយ រមែងមានសេចក្តីក្លៀវក្លា អង់អាច មិនក្រអឺមក្រអៀម.

៥- **សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** អ្នកឱ្យទាន លុះបែកធ្លាយរាងកាយឃ្លាតចាកលោកនេះ ក៏ទៅកើតឯសុគតិសួគ៌ទេវលោក. លុះច្យុតិចាកទេវលោក ដោយអំណាចឧស្សន្នកុសលជាប់មក ក៏បានកើតមកក្នុងមនុស្សលោកនេះទៀត រមែងកើតក្នុងត្រកូលខ្ពស់ ដែលសម្បូណ៌ដោយភោគសម្បត្តិ។

# អានិសង្សអាមិសទាន

ជាបុគ្គលាធិដ្ឋាន

## រឿងបណ្ឌិតសាមណេរ

កាលកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ មានព្រះខីណាស្រពជាបរិវារ ទ្រង់ស្តេចទៅកាន់ក្រុងពារាណសី ។

មនុស្សទាំងឡាយក៏ចងគ្នាជាពួក បាន ៨ នាក់ខ្លះ ១០ នាក់ខ្លះប្រគេនអាគន្តុកទាន ។ កាលដែលព្រះសាស្តាធ្វើភត្តានុមោទនាចប់ មានបណ្ឌិតបុរសម្នាក់ថ្វាយបង្គំព្រះសាស្តានិមន្តថា "បពិត្រព្រះអង្គដ៏ចំរើន. សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ព្រមទាំងព្រះសង្ឃជាបរិវារទាំងអស់" ហើយបុរសនោះចូលទៅឃោសនាក្នុងស្រុក ។ មនុស្សទាំងឡាយខ្លះទទួលថា យើងប្រគេនចង្ហាន់ដល់ភិក្ខុ ១០ អង្គ ខ្លះថា ២០ អង្គ ខ្លះថា ១០០ អង្គ ។ បណ្ឌិតបុរសកត់ឈ្មោះដាក់ក្នុងបញ្ជីតាំងពីដើមរៀងមក។ សម័យនោះឯងមានបុរសម្នាក់ ឈ្មោះមហាទុគ្គត នៅក្នុងនគរនោះ ជាមនុស្សទាល់ក្រក្រៃពេក បានទទួលពាក្យបណ្ឌិតបុរសថា "បើដូច្នោះ ចូរអ្នកកត់ចំនួនភិក្ខុ ១ អង្គ ក្នុងបញ្ជីទុកឱ្យខ្ញុំផងចុះ" ហើយទៅប្រាប់ភរិយាថា ម្នាលនាង គេបបួលយើងឱ្យទទួលភិក្ខុ ១ អង្គ មកប្រគេនចង្ហាន់ក្នុងថ្ងៃស្អែក ។ ភរិយាទទួលអំណរឥតត្អូញត្អែរ. ហើយនាំគ្នាទៅរកធ្វើការឈ្នួល ។ មហាសេដ្ឋីបានឃើញមហាទុគ្គតដើរមក ក៏មានប្រសាសន៍ថា ស្អែកយើងនិមន្តព្រះសង្ឃពីរបីរយអង្គមកឆាន់. ចូរអ្នកឯងពុះ

ឱសឱ្យយើងចុះ ។ មហាទុគ្គតក៏ចងក្បិនយ៉ាងមាំ ហើយខំប្រឹងយ៉ាងខ្លាំង. បោះកាំបិតចាប់ប៉ូវថៅ. បោះប៉ូវថៅចាប់កាំបិត ។

សេដ្ឋីសួរថា ហេតុដូចម្ដេចបានជាថ្ងៃនេះ អ្នកឯងប្រឹងធ្វើការដល់ម្ល៉េះ ? បពិត្រលោកម្ចាស់. ស្អែកនេះខ្ញុំប្របាទប្រគេនចង្ហាន់ភិក្ខុ ១ អង្គដែរ ។

សេដ្ឋីឮហើយក៏មានចិត្តត្រេកអរណាស់ ។ ឯភរិយាសេដ្ឋី ក៏សួរប្រពន្ធមហាទុគ្គតដូច្នោះដែរ ។

លុះមហាទុគ្គត ពុះឱសរួចហើយ. សេដ្ឋីឱ្យបម្រើយកអង្ករស្រូវសាលី ៤ នាឡិមកឱ្យ. ហើយប្រាប់ថា: នេះជាថ្លៃឈ្នួល. ឱ្យអង្ករ ៤ នាឡិទៀតប្រាប់ថា: នេះជារង្វាន់នៃសេចក្ដីត្រេកអររបស់អ្នក ។

ឯភរិយាសេដ្ឋីឱ្យបម្រើសេដ្ឋីយកសប្បិ ១ ដប ទធិ ១ ភាជន គ្រឿងសម្ល ១ បង្វិច និងអង្ករស្រូវសាលី ១ នាឡិមកឱ្យប្រពន្ធមហាទុគ្គត ។ ព្រឹកឡើងមហាទុគ្គតដើរស្វែងរកបន្លែឯឆ្នេរស្ទឹង. មានចិត្តរីករាយសប្បាយក្រៃពេក ទើបស្រែកច្រៀងបណ្ដើរបេះបន្លែបណ្ដើរ ។ ព្រានប្រមង់ (អ្នកបង់សំណាញ់) ម្នាក់ បានឮសំឡេងច្រៀងហើយ ក៏ស្រែកហៅមហាទុគ្គតមក ឱ្យដោតត្រីជាត្រណោត១ ចំនួនថ្លៃ ១ បាទខ្លះ កន្លះបាទខ្លះ ១ កហាបណៈខ្លះ ។ អ្នកនគរទាំងឡាយ មកទិញត្រីទាំងនោះអស់ទៅ ។ មហាទុគ្គតកំណត់វេលាហើយ ក៏និយាយលាព្រាននោះ ព្រាននោះបានឱ្យត្រីឆ្អិន[១] ៤ ដែលខ្លួនកប់ទុកនៅផ្នុកខ្សាច់ ។

សម័យនោះឯង ព្រះសាស្ដាទ្រង់ប្រមើលមើលនូវឧបនិស្ស័យនៃសត្វ

---

១- ច្បាប់ខ្លះហៅត្រីថ្កិន. ច្បាប់ខ្លះហៅត្រីឆ្អិន. តាមនិយមស្រុក ។

សត្វលោក. ទ្រង់ឃើញមហាទុគ្គតចូលក្នុងសំណាញ់ញាណរបស់ព្រះអង្គ. ហើយទ្រង់គង់ចាំក្នុងគន្ធកុដិ ។ កាលមហាទុគ្គតយូរត្រីទៅដល់ផ្ទះ ថ្មបណ្ឌុកម្ពលសិលាអាសន៍របស់សក្កទេវរាជ ក៏បញ្ចេញកំដៅឡើង. ទើបសក្កទេវរាជទ្រង់អាវជ្ជនាការជ្រាបហេតុនោះសព្វគ្រប់ហើយ ក៏ក្លែងភេទមិនឱ្យអ្នកណាស្គាល់សោះ មកជួយចាត់ចែងភិក្ខាហារ ហើយបញ្ជូនមហាទុគ្គតឱ្យទៅទទួលលោកមក ។

ឯបណ្ឌិតបុរសជាអ្នកចាត់ចែងទាន បានបញ្ជូនភិក្ខុទាំងឡាយឱ្យទៅផ្ទះជនទាំងនោះ តាមចំនួនដែលមាននៅក្នុងបញ្ជី ។ មហាទុគ្គតទៅដល់បណ្ឌិតបុរសនិយាយថា ខ្ញុំភ្លេចឈឹង. មិនបានទុកភិក្ខុ ១ អង្គឱ្យអ្នកឯងទេ ។ មហាទុគ្គតក៏ភ្ញាក់ក្នុងចិត្ត ហាក់ដូចជាគេចាក់ត្រង់ពោះដោយលំពែងដ៏មុត ហើយនិយាយថា "នែអ្នក. ហេតុអ្វីក៏អ្នកធ្វើខ្ញុំឱ្យវិនាស. អ្នកពិតជាបបួលខ្ញុំលលាំងៗពីថ្ងៃម្សិលមិញ បានជាខ្ញុំខំធ្វើការទាំងម្ល៉េះ. ហើយក៏លម្យ៉ានៅទីនោះ ។

ទើបបណ្ឌិតបុរសនិយាយថា នែមហាទុគ្គតជាសំឡាញ់. ធ្វើម្តេចខ្ញុំបានជាប្រហែសជ្រុលទៅហើយ. ប៉ុន្តែឥឡូវនេះ ព្រះសាស្តាកំពុងគង់នៅក្នុងគន្ធកុដិនៅឡើយ. បើដូច្នេះ ចូរអ្នកឯងទៅអង្វរករនិមន្តព្រះអង្គលមើល ក្រែងជូនជាទ្រង់សង្គ្រោះ ។ កាលបើមហាទុគ្គតទៅដល់. ព្រះសាស្តាក៏បើកទ្វារគន្ធកុដិចេញមក. ទ្រង់ហុចបាត្រដល់ដៃមហាទុគ្គត មហាទុគ្គតក៏ហាក់ដូចជាបានទូវសិរីសម្បត្តិរបស់ស្តេចចក្រ ។ ឯព្រះរាជានិងអនុរាជជាដើម ដែលមកត្រៀមចាំទទួលបាត្រក៏ងាកមើលមុខគ្នាមិនមាននរណាហ៊ានយកបាត្រ ដែលព្រះអង្គទ្រង់ប្រទានដល់មហាទុគ្គតដោយឥស្សរិយយសរបស់ខ្លួនឡើយ. គ្រាន់តែនិយាយដូច្នេះថា ម្នាល

មហាទុគ្គតជាសំឡាញ់. ចូរអ្នកឱ្យបាត្រព្រះអង្គមកយើងវិញ. យើងនឹងឱ្យទ្រព្យ ១ ពាន់កហាបណៈ. ១ សែនកហាបណៈដល់អ្នក ។ មហាទុគ្គតមិនព្រមសោះ ។ ចំណែកខាងសក្កទេវរាជបានចាត់ចែងយាគូ និងភត្តហើយក៏ក្រាលអាសនៈ បម្រុងចាំព្រះអង្គ ។ ឯផ្ទះមហាទុគ្គតនោះទាបក្រៃពេក បើនរណាមិនដើរឱន. មិនអាចចូលទៅបានឡើយ. ប៉ុន្តែកាលដែលព្រះសាស្ដាទ្រង់និមន្តចូលទៅ. មហាប្រឹថពីក៏ស្រុតចុះទៅក្រោមគេហស្ថានក៏អណ្ដែតឡើងខាងលើ. ទ្រង់ចូលទៅដោយមិនបាច់ឱនឡើយ ។ គ្រានោះសក្កទេវរាជ បើកគ្របភាជនចង្ហាន់ឡើង ក៏ក្លិនវត្ថុទាំងនោះក្រអូបឈ្ងុយឈ្ងប់ផ្សាយចេញទៅពេញនគរទាំងអស់ ។

ព្រះសាស្ដាទ្រង់ទទួលចង្ហាន់ធ្វើភត្តកិច្ចអនុមោទនារួចហើយ ទ្រង់ក្រោកចាកអាសនៈនិមន្តចេញទៅ សក្កទេវរាជនិងមហាទុគ្គតក៏យកបាត្រជូនដំណើរព្រះអង្គទៅវិហារ ។ លុះសក្កទេវរាជត្រឡប់មកវិញ ក៏ឋិតនៅទៀបទ្វារផ្ទះមហាទុគ្គត ហើយងើបមើលអាកាស. ភ្លៀងកែវ ៧ ប្រការក៏ធ្លាក់ចុះពីអាកាសមកចូលពេញភាជនពេញផ្ទះទាំងមូល ។ ភរិយាមហាទុគ្គតដឹកដៃកូនរត់ចេញមកឈរនៅខាងក្រៅ ។ មហាទុគ្គតក៏ក្រាបបង្គំទូលព្រះរាជាថា ផ្ទះទូលព្រះបង្គំជាខ្ញុំពេញដោយរតនៈ ៧ ប្រការ គ្មានឱកាសកន្លែងណាទេ ។ ព្រះរាជាទ្រង់បញ្ជូនរទេះ ១ ពាន់ឱ្យទៅដឹកទ្រព្យនោះមកចាក់គរជាគំនរក្នុងព្រះរាជលាន. ហើយទ្រង់ឱ្យប្រជុំអ្នកនគរមកធ្វើសក្ការៈបូជាដល់មហាទុគ្គតនោះ ហើយទ្រង់ព្រះរាជទាននាទីជាសេដ្ឋី ។ គ្រានោះឯង ព្រះរាជាទ្រង់ប្រាប់កន្លែងគេហស្ថានចាស់ដែលសេដ្ឋីម្នាក់នៅពីមុន ឱ្យមហាជនកាប់គាស់គល់ឈើក៏ប្រទះកំណប់

ទ្រព្យជាច្រើនក្នុងទីនោះ ។ ព្រះរាជាទ្រង់ព្រះរាជទានកំណប់ទ្រព្យនោះដល់សេដ្ឋីនោះទៀត ។

សេដ្ឋីនោះបានប្រគេនចង្ហាន់ដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ។ លំដាប់ពីនោះមកតែងធ្វើបុណ្យមិនដែលដាច់ ដរាបដល់អស់អាយុសង្ខារ ក៏បានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិអស់ ១ ចន្លោះព្រះពុទ្ធ. ដល់ព្រះពុទ្ធជាម្ចាស់យើងនេះឧប្បត្តិឡើង ក៏ច្យុតអំពីទេវលោកមកចាប់បដិសន្ធិក្នុងគភ៌នៃធីតាជាច្បង ក្នុងត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្តត្ថេរ នៅក្នុងក្រុងសាវត្ថី ។ (កុមារនោះបានចូលបួសក្នុងព្រះពុទ្ធសាសនាមាននាមប្រាកដថា "បណ្ឌិតសាមណេរ" បានសម្រេចអរហត្តព្រមទាំងបដិសម្ភិទាតាំងពីជន្មាយុ ៧ ឆ្នាំ) ។

## សម្បទា ឧម្ពជាតិធ្វើទានឱ្យមានផល ៣ យ៉ាងគឺ:

**១. វត្ថុសម្បទា** ដល់ព្រមដោយវត្ថុ គឺទេយ្យវត្ថុដែលកើតឡើងដោយត្រឹមត្រូវតាមធម៌ ។

**២. ចេតនាសម្បទា** ដល់ព្រមដោយចេតនាទាំង ៣ គឺ បុព្វចេតនា ១. មុញ្ចនចេតនា ១. អបរាបរចេតនា ១ ។

**៣. បុគ្គលសម្បទា** ដល់ព្រមដោយបុគ្គលដែលគួរបូជា គឺបដិគ្គាហកៈអ្នកប្រតិបត្តិត្រឹមត្រូវល្អ ។

# ទានដែលមានផលានិសង្សច្រើន

លុះតែប្រកបដោយអង្គ ៦ យ៉ាងគឺ:

◆◆◆◆◆◆

អង្គខាងអ្នកឱ្យ ៣ យ៉ាង-អ្នកទទួល ៣ យ៉ាង

អង្គខាងអ្នកឱ្យ ៣ យ៉ាង គឺ:

**១. បុព្វេវ ទានា សុមនោ ហោតិ** អ្នកឱ្យមានចិត្តត្រេកអរក្នុងកាលមុនឱ្យ.

**២. ទទំ ចិត្តំ បសាទេតិ** អ្នកឱ្យញុំាងចិត្តឱ្យជ្រះថ្លាក្នុងកាលកំពុងឱ្យ.

**៣. ទត្វា អត្តមនោ ហោតិ** អ្នកឱ្យទានមានចិត្តត្រេកអរចំពោះទានដែលបានឱ្យរួចហើយ ។

អង្គទាំង ៣ យ៉ាងនេះហៅដោយខ្លីថា:

បុព្វចេតនា ១. មុញ្ចនចេតនា ១. អបរាបរចេតនា ១ ដូច្នេះវិញក៏បាន ។

អង្គខាងអ្នកទទួល ៣ យ៉ាង គឺ:

**១. វីតរាគា វា ហោន្តិ រាគវិនយាយ វា បដិបន្នា** បដិគ្គាហកៈ អ្នកទទួលទាន មានរាគៈទៅប្រាស (ពីខន្ធសន្តាន) ហើយ ឬ កំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវរាគៈ.

**២. ទីតះទោសា ទា ហោន្តិ ទោសវិនយាយ ទា បដិបន្នា** បដិគ្គាហកៈ អ្នកទទួលទាន មានទោសៈទៅប្រាស (ពីខន្ធសន្តាន) ហើយ ឬ កំពុង ប្រតិបត្តិដើម្បីកំចាត់បង់នូវទោសៈ.

**៣. ទីតះមោហា ទា ហោន្តិ មោហវិនយាយ ទា បដិបន្នា** បដិគ្គាហកៈ អ្នកទទួលទាន មានមោហៈទៅប្រាស (ពីខន្ធសន្តាន) ហើយ ឬ កំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវមោហៈ.

រួមអង្គទាំងពីរចំណែក គឺទាំងអ្នកឱ្យ-ទាំងអ្នកទទួលត្រូវជា ៦ យ៉ាង ហៅថា ឆឡង្គទាន ប្រែថា ទានប្រកបដោយអង្គ ៦ ។

ទានប្រកបដោយអង្គ ៦ យ៉ាងនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សរសើរ ថា នឹងបានអានិសង្សច្រើន មិនអាចនឹងគណនាត្រារាប់ថាចំនួនប៉ុណ្ណេះប៉ុណ្ណោះ បានឡើយ ។

## សីលសម្បត្យានិសំសកថា

**សីល** បានសម្រេចផល ៣ យ៉ាងគឺៈ

១- សោតាបត្តិផល. ២- សកិទាគាមិផល. ៣- អនាគាមិផល. និងមគ្គមួយខាងលើ- គឺអរហត្តមគ្គ ។

**សីល** > សីធាតុ + លុបច្ច័យ. ប្រែថាៈ ក្រៀកនូវ "កុសល"

ប្រែតាមអត្ថមាន ៥ យ៉ាង គឺៈ

**១. សមោធានដ្ឋោ** ប្រែថា ប្រជុំនូវសុចរិត.

២. ឧបគរនេត្តោ ប្រែថា ទ្រទ្រង់ឱ្យខ្ពង់ខ្ពស់.

៣. សីនេត្តោ ប្រែថា ចំរើន.

៤. សីលេត្តោ ប្រែថា ប្រក្រតី.

៥. សីតលេត្តោ ប្រែថា ត្រជាក់ ។

បន្ទាប់ពីនេះ សូមលើកយកនូវអានិសង្សសីលសម្បត្តិដូចតទៅ:

សីលនេះ កាលបើបុគ្គលបានរក្សាធ្វើឱ្យបរិសុទ្ធម៉ត់ចត់ហើយ អាចនឹងមានអានិសង្សច្រើនជាអនេក មានសេចក្តីមិនក្តៅក្រហាយជាដើម ។

ន័យខ្លះព្រះមានព្រះភាគទ្រង់ត្រាស់សំដែងទុកថា មានអានិសង្ស ៥ យ៉ាងដូចខាងមុខនេះ :

## អានិសង្សសីល ៥ យ៉ាង:

**១.អប្បមាទោ អធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ** អ្នកនោះនឹងបាននូវគំនរទ្រព្យដ៏ច្រើន មិនមានអធិករណ៍ព្រោះសេចក្តីមិនប្រមាទ.

**២.កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** នឹងមានកេរ្តិ៍ឈ្មោះពីរោះល្អ ជាកល្យាណ កិត្តិសព្ទផុសអណ្តែតឡើង.

**៣.វិសារទោ ឧបសង្កម អមង្កុភូតោ** កាលនឹងចូលទៅកាន់ទីប្រជុំ តែងរីករាយមិនមានអៀនអន់ ដាក់មុខសំយុងចុះ.

**៤.អសម្មុឡ្ហោ កាលំ ករោតិ** វេលានឹងធ្វើកាលកិរិយាមិនវង្វេង

ស្ថានតី.

**៥-កាយស្ស ភេទា បរម្មរណា សុគតី សគ្គំ លោកំ ឧបបជ្ជតិ** បន្ទាប់ពីការបែកធ្លាយខន្ធទៅ តែងបានទៅកើតក្នុងសុគតិស្ថានសួគ៌។

មិនត្រឹមតែប៉ុណ្ណោះឡើយ បុគ្គលដែលមានសីលរមែងបានជាទីស្រឡាញ់ពេញចិត្តនិងជាទីគោរពសរសើរព្រហ្មចារីផងគ្នាជាដើម ដរាបទៅទល់ត្រឹមបានដល់នូវព្រះនិព្វាន ដែលជាគ្រឿងក្ស័យនៃអាសវៈជាទីបំផុត សមដូចជាគាថាច្រើនបទដែលលោកពោលទុកជាសំអាងដូច្នេះ :

**សាសនេ កុលបុត្តានំ បតិដ្ឋា នត្ថិ វិនា**
**អានិសំសបរិច្ឆេទំ តស្ស សីលស្ស កោវទេ ។**

សេចក្ដីថា ទីពឹងផ្អែកនៃកុលបុត្រទាំងឡាយក្នុងសាសនា វៀរលែងតែសីលចេញ មិនមានសោះឡើយ កាលបើដូច្នេះ បុគ្គលណាសោតក៏នឹងគប្បីពោលកំណត់នូវអានិសង្សនៃសីលនោះបាន ?

**ន គង្គា យមុនា ចាបិ សរភូ វា សរស្សតិ**
**និន្នគា វា ចិរវតី មហី ចាបិ មហានទី**
**សក្កុណន្តិ វិសោធេតុំ តំ មលំ ឥធ បាណិនំ**
**វិសោធយតិ សត្តានំ យំ វេ សីលជលំ មលំ ។**

ទឹកស្ទឹងគង្គាក្ដី យមុនាក្ដី សរភូក្ដី សរស្សតិក្ដី អចិរវតីក្ដី មហីក្ដី[១] សុទ្ធ

(១) ក្នុងដីកាប្រាប់ថាស្ទឹង គោធាវរី និងស្ទឹងចន្ទភាគាជាដើម ក៏សង្គ្រោះចូលក្នុងទីនេះដែរ។

តែជាស្ទឹងយ៉ាងធំៗ ក៏មិនអាចដើម្បីនឹងជំរះនូវមន្ទិលរបស់សត្វទាំងឡាយក្នុងលោកនេះបានឡើយ មានតែទឹកពោលគឺសីលនេះឯងហើយ ទើបអាចជំរះនូវមន្ទិលរបស់សត្វទាំងឡាយបាន ។

**ន តំ សជលា ទាតា    នចាបិ ហរិចន្ទនំ**
**នេវ ហារា ន មណយោ    ន ចន្ទកិរណង្កុរា**
**សមយន្តីធ សត្តានំ    បរិឡាហំ សុរក្ខិតំ**
**យំ សមេតិទំ អរិយំ    សីលំ អច្ចន្ត សីតលំ ៕**

ខ្យល់ទាំងឡាយដែលប្រកបដោយទឹកក្តី ខ្លឹមចន្ទន៍ក្រហមក្តី កែវមុក្តាហារទាំងឡាយក្តី កែវមណីទាំងឡាយក្តី រស្មីនៃព្រះចន្ទដ៏ទន់ក្តី មិនអាចដើម្បីនឹងរម្ងាប់ នូវសេចក្តី ក្រហល់ក្រហាយរបស់សត្វទាំងឡាយក្នុងលោកនេះបានឡើយ មានតែសីលដ៏ប្រសើរ ដែលបុគ្គលរក្សាហើយដោយប្រពៃ ជាគុណជាតិត្រជាក់យ៉ាងក្រៃលែង នេះទើបអាចដើម្បីរម្ងាប់បាន ។

**សីលគន្ធសមោ គន្ធោ    កុតោ នាម ភវិស្សតិ**
**យោ សមំ អនុវាតេ ច    បដិវាតេ ច វាយតិ ៕**

ក្លិនដែលអាចផាត់ទៅបានស្មើទាំងបណ្តោយខ្យល់ទាំងច្រាស់ខ្យល់ឱ្យប្រហែលដោយក្លិនរបស់សីល នឹងមានមកអំពីទីណា ?

**សគ្គារោហណសោបានំ    អញ្ញំ សីលសមំ កុតោ**
**ទ្វារំ វា បន និព្វាន    នគរស្ស បវេសនេ ៕**

ធម្មជាតិដទៃ ដែលជាជណ្តើរសម្រាប់ឡើងទៅកាន់ស្ថានសួគ៌ ឬ ថាជា

ទ្វារសម្រាប់ញុំាងជន ឱ្យចូលទៅកាន់នគរនិព្វាន ឱ្យស្មើដោយសីលនឹងមានមក អំពីទីណា ?

**សោភន្តេវន្ន រាជានោ មុត្តាមណិវិភូសិតា**
**យថា សោភន្តិ យតិនោ សីលភូសនភូសិតា ៕**

ព្រះរាជាទាំងឡាយ ដែលស្អិតស្អាងដោយកែវមុក្តានិងកែវមណី ក៏ទុកថាជាសមល្អមែនហើយ តែមិនសមល្អដូចជា ព្រះយោគីទាំងឡាយដែលស្អិតស្អាងហើយ ដោយគ្រឿងសំអាង ពោលគឺសីលនោះឡើយ ។

**អត្តានុវាទាទិភយំ វិទ្ធំសយតិ សព្វសោ**
**ជនេតិ កិត្តិ ហាសញ្ចសីលំ សីលវតំសទា ៕**

សប្បុរសអ្នកមានសីលទាំងឡាយ តែងកំចាត់បង់នូវភ័យទាំងពួងមាន អត្តានុវាទភ័យ[១] ជាដើម មិនឱ្យមានសេសសល់ផង តែងញុំាងកិត្តិសព្ទ និងសេចក្ដីរីករាយ ឱ្យកើតឡើងសព្វ១ កាលផង ។

# អានិសង្សសីល

ជាបុគ្គលាធិដ្ឋាន

*****

សេចក្ដីថា: មានឈ្មួញជាច្រើននាក់នាំគ្នាទៅជួញដោយសំពៅទៅក្នុងសមុទ្រ បានបើកសំពៅយ៉ាងលឿនរហ័សប្រៀបដូចជាគេបាញ់កូនសរ បាន ៧ ថ្ងៃក៏កើតឧទ្ទបាទវ៍ ដោយខ្យល់ព្យុះព្យោមាបក់បោកជាខ្លាំងរលកធំ១ ក៏បោក

---

(១) ភ័យអំពីការតិះដៀលខ្លួនឯង គឺតូចចិត្តខ្លួនឯង ។

ខ្ចប់លើសំពៅនោះបណ្ដាលឱ្យទឹកចូលពេញ ។ កាលសំពៅទៀបនឹងលិច មហាជនបាននាំគ្នានឹករលឹកដល់ទេព្តារៀង១ ខ្លួនមានធ្វើកិច្ចបន់ស្រន់ជាដើម ដើម្បីឱ្យទេព្តាជួយអាយុជីវិត. ហើយនាំគ្នាយំពេញតែសំពៅ ។ ប្លែកតែបុរសម្នាក់ បាននឹករលឹកគិតពិចារណាខុសគេថា អាត្មាអញមានអ្វីជាទីពឹងនៅគ្រាមានអាសន្នដូច្នេះ ក៏នឹកឃើញដល់សរណគមន៍ និងសីលដ៏បរិសុទ្ធរបស់ខ្លួន ទើបអង្គុយពែនភ្នែនក្នុងចំណោមមហាជនទាំងនោះ ប្រៀបដូចព្រះយោគីអង្គុយចំរើនកម្មដ្ឋាន ។ មហាជនសួរបុរសនោះថា ហេតុអ្វីបានជាអ្នកមិនខ្លាចសេចក្ដីស្លាប់ ?

ម្នាលអ្នកទាំងឡាយ ថ្ងៃដែលយើងឡើងជិះសំពៅមក យើងបានឱ្យទានដល់ភិក្ខុសង្ឃបានសមាទានសរណគមន៍ និងសីលរួចជាស្រេច ព្រោះហេតុនោះបានជាយើងមិនខ្លាច ។ មហាជនសួរថា អ្នកជាម្ចាស់អ្នកអាចឱ្យដល់អ្នកដទៃបានឬទេ? បាន ។ បើដូច្នោះ សូមអ្នកឱ្យដល់យើងផង ។ បុរសនោះ ក៏រំលែកមហាជនជា ៧ ចំណែក. មួយចំណែកមាន ១០០ រូប ទើបឱ្យនិច្ចសីលដល់មហាជនទាំងអស់គ្នា ។ បណ្ដាជនទាំង ៧ ក្រុមនោះ ក្រុមទី ១ សមាទានសីលក្នុងវេលាទឹកត្រឹមកជើង ក្រុមទី ២ ក្នុងវេលាទឹកត្រឹមជង្គង់. ក្រុមទី ៣ ទឹកត្រឹមចង្កេះ. ក្រុមទី ៤ ទឹកត្រឹមផ្ចិត. ក្រុមទី ៥ ទឹកត្រឹមដោះ. ក្រុមទី ៦ ត្រឹមក. ក្រុមទី ៧ សមាទានសីលក្នុងវេលាទឹកប្រែចូលមាត់ ។ លុះឱ្យសីលដល់មនុស្សទាំងអស់រួចហើយ បុរសនោះស្រែកប្រកាសថា អ្នករាល់គ្នាគ្មានអ្វីទីពឹងក្រៅពីសីលរបស់ខ្លួនទេ ចូរពិចារណាសីលតែម្យ៉ាងបានហើយ ។ ពួកជន

ទាំង ៧០០ ក៏ធ្វើមរណៈកាលកណ្តាលសមុទ្រនោះ បានទៅកើតនាស្ថានត្រៃត្រឹង្សទេវលោកទាំងអស់គ្នា ព្រោះអាស្រ័យសីលដែលខ្លួនបានសមាទានក្នុងពេលជិតស្លាប់ ។ វិមានទាំងឡាយក៏កើតដល់ទេវបុត្រទាំងនោះជាពួកជាក្រុម ។ វិមានមាសកំពស់ ១០០ យោជន៍ កើតឡើងដល់ទេវបុត្រជាអាចារ្យ ចំកណ្តាលវិមានទាំងអស់ ។ វិមាន យ៉ាងទាបបំផុតត្រឹម១២យោជន៍ ។ ទេវបុត្រទាំងនោះពិចារណាមើលបុញ្ញកម្ម ក្នុងខណៈដែលខ្លួនទៅកើតរួចហើយ ក៏ដឹងច្បាស់ថា សម្បត្តិដែលខ្លួនបាននេះ ព្រោះអាស្រ័យទេវបុត្រជាអាចារ្យ ទើបនាំគ្នាហោះមកសរសើរគុណអាចារ្យ ក្នុងសំណាក់ព្រះសាស្តាដោយបការៈផ្សេងៗពីគ្នា ។

សីលសម្បត្យានិសំសកថាចប់

*****

## អានិសង្សអ្នកសំដែងធម៌ ៤ យ៉ាងគឺៈ

**១. អត្ថប្បដិសំភេទា ធម្មប្បដិសំភេទា** លោកអ្នកសំដែង កាលបើសំដែងដោយផ្ចិតផ្ចង់ តាមអង្គនៃធម្មកថិកចំពោះព្រះសទ្ធម្ម នឹងរឹងរឹតតែជាអ្នកយល់ធ្លុះធ្លាយក្នុងអត្ថនិងធម៌ យ៉ាងក្រៃលែងទៅទៀត.

**២. ធម្មោជ្ជ** សេចក្តីរីករាយក្នុងអត្ថនិងធម៌រមែងកើតឡើង គឺធម្មទេសនានោះ ក៏ពីរោះចាប់ចិត្តខ្លួនឯងនិងបុគ្គលអ្នកស្តាប់ តាមលំដាប់នៃធម៌ដែលកើតឡើង.

៣. **បីតិ** សេចក្ដីត្រេកអរមទាំងមានកម្លាំង ឆ្អែតចិត្តក្នុងធម៌នោះៗ ក៏កើត ឡើង.

៤. **បស្សទ្ធិ** រូបកាយនិងនាមកាយរបស់លោកអ្នកសំដែង និងអ្នកស្ដាប់ក៏ស្ងប់រម្ងាប់ចាកអកុសលធម៌ផ្សេងៗ ដរាបដល់ចិត្តសង្វេគតក់ស្លុតក្នុងសង្ខារទាំងឡាយ.

៥. **សមាធិ** ចិត្តរបស់លោកដែលកំពុងសំដែងក៏តាំងមាំក្នុងការស្ងាត់ចាកនីវរណៈ ។

អានិសង្ស ៥ យ៉ាងនេះ ជាសន្ទិដ្ឋិកផល គឺផលគប្បីឃើញច្បាស់ក្នុងបច្ចុប្បន្នក៏មាន. ជាសម្បរាយិកផល គឺផលត្រូវជាប់ទៅបរលោកក៏មាន ។

## ឧបនិស្ស័យការស្ដាប់ធម៌ ៤ យ៉ាងទៀត

១. **សោតានុគតា** ជាប្រឡាយទៅកាន់សោតា.

២. **ឧគណ្ហន្តិ** រៀនយកនូវព្រះសូត្រ-ព្រះវិន័យ-អភិធម្ម.

៣. **វាចនំ** ប្រាប់ធម៌ សំដែងធម៌ដល់អ្នកដទៃ.

៤. **សជ្ឈាយំ** ស្វាធ្យាយទន្ទេញ ។

## ផលនៃការស្ដាប់ធម៌ ៤ យ៉ាងគឺ៖

១. **ពុទ្ធសាសនំ ចិរំ ឋិតិ** នឹងញ៉ាំងព្រះពុទ្ធសាសនាឱ្យរុងរឿង

២. **ពហុស្សុតោ** នឹងបានចេះដឹងនូវពុទ្ធវចនៈច្រើន.

៣. **សុគតិបរាយនោ** លុះស្លាប់ទៅនឹងបានទៅសុគតិខាងមុខ.

៤. បដិវេធ: ទឹងបានត្រាស់ដឹងនូវមគ្គ និង ផល ។

## អានិសង្សអ្នកស្ដាប់ ៥ យ៉ាង គឺ:

១. អស្សុតំ សុណាតិ អ្នកស្ដាប់ធម៌រមែងបានស្ដាប់នូវធម៌ដែលមិនធ្លាប់បានស្ដាប់ .

២. សុតំ សុណាតិ អ្នកស្ដាប់ធម៌រមែងបានស្ដាប់នូវធម៌ដែលមិនធ្លាប់បានស្ដាប់រឿយៗ.

៣. កង្ខំ វិហនតិ បានកំចាត់បង់នូវសេចក្ដីសង្ស័យ.

៤. ទិដ្ឋឹ ឧជុំ ករោតិ អ្នកស្ដាប់ធម៌នឹងធ្វើនូវទិដ្ឋិឱ្យត្រង់ឡើង.

៥. ចិត្តមស្ស បសីទតិ អ្នកស្ដាប់ធម៌នឹងញ៉ាំងចិត្តឱ្យរីងរឹតតែជ្រះថ្លាឡើង ។

អានិសង្សទាំង ៥ យ៉ាងនេះ ក៏ជាសន្ទិដ្ឋិកផល គឺផលគួរបានក្នុងបច្ចុប្បន្នក៏មាន. ជាសម្បរាយិកផល គឺផលគួរបានក្នុងបរលោកក៏មាន ។

## អានិសង្សនៃការស្ដាប់ធម៌

ជាបុគ្គលាធិដ្ឋាន

## រឿងព្រះឥន្ទនិម្មិតជាយក្ខ

កាលពីព្រេងនាយមានព្រះរាជាមួយព្រះអង្គព្រះនាម ធម្មសោណ្ឌកៈ តាំងពីបានទទួលរាជាភិសេកមក ទ្រង់មានបំណងតែមួយ គឺចង់ស្ដាប់ព្រះសទ្ធម្ម-

ទេសនា បានចាត់ព្រះរាជបំរើឱ្យយកប្រាក់តាំងពី ១ ពាន់កហាបណៈដរាបដល់ ១ កោដិ ទៅរកជូលអ្នកចេះសំដែងធមិមកសំដែងឱ្យស្តាប់មិនបានសោះ ក៏លះបង់រាជសម្បត្តិត្រាច់ទៅរកស្តាប់ធមិដោយព្រះអង្គឯង ។

ក្នុងពេលនោះព្រះឥន្ទបានជ្រាបហើយ ក៏និម្មិតជាយក្ខធំអស្ចារ្យមានអាការៈសម្បើមគួរឱ្យខ្លាច គឺមានសម្បុរដូចជាកំពូលភ្នំអញ្ជ័ន. មាត់ធំ មានចង្កូមលៀនចេញមកក្រៅ. ភ្នែកធំក្រហមច្រាលដូចគំនរភ្លើងកំពុងឆេះ. ថ្ពុងខ្ទង់ ច្រមុះមានចុងក្រហម. សក់ និង ពុកមាត់ពុកចង្កាពណ៌ទង់ដែងរួញក្រញាញ់. ពោះធំពណ៌ខៀវ. សម្លេងគ្រហឹមឮដូចផ្គរលាន់. ដៃមានក្រចកវែង១ប្រឡាក់សុទ្ធតែឈាម មានដំបងគ្រឿងសស្ត្រាវុធជាប់នៅដៃ មាឌធំខ្ពស់ស្មើត្នោតលៃ ចូលទៅឈរកៀកជិតព្រះធម្មសោណ្ឌកៈរាជ១ បានឃើញយក្ខនោះហើយ ឥតមានខ្លាចញាប់ញ័រឡើយ. បែរជាមានព្រះតម្រិះថា យក្ខដែលមានអានុភាពបែបនេះ ប្រហែលជាចេះសំដែងធមិ ក៏ទ្រង់មានព្រះតម្រាស់ត្រាស់សួរទៅយក្សថាៈ បពិត្រមហាយក្ខជាសម្លាញ់អ្នកមានអានុភាពច្រើន មានអាការៈក្លាហាន បានមកជួបយើងប្រសើរណាស់ ព្រោះយើងបានលះបង់រាជសម្បត្តិ និងព្រះរាជវង្ស ចូលមកក្នុងព្រៃនេះដើម្បីរកអ្នកចេះធមិទេសនាឱ្យស្តាប់ ឥឡូវនេះបើអ្នកចេះធមិសូមសំដែងឱ្យយើងស្តាប់ ។

ឥន្ទយក្ខនិយាយតបវិញថា : បពិត្រមហារាជ យើងបានចេះធមិដែលព្រះពុទ្ធពីបុរាណទ្រង់បានសំដែងទុកមក ប៉ុន្តែបើយើងសំដែងថ្វាយព្រះអង្គស្តាប់ តើព្រះអង្គបូជាអ្វីដល់យើង ។ ព្រះបាទធម្មសោណ្ឌកៈរាជ ទ្រង់មានព្រះបន្ទូល

ថាយើងគ្មានអ្វីទេ មានតែសរីរកាយរបស់យើងនេះឯង សូមបូជាធមិរបស់អ្នក បើអ្នកសំដែងធមិឱ្យយើងស្តាប់ ចូរអ្នកបរិភោគយើងចុះ ។

ឥន្ទយក្ខថាស្រួលហើយ ប៉ុន្តែយើងអស់កម្លាំងណាស់ព្រោះអត់អាហារយូរថ្ងៃហើយ បើបានបរិភោគឱ្យមានកម្លាំងសិន ទើបសំដែងធមិថ្វាយមហារាជបាន ។

ក្នុងលំដាប់នោះព្រះរាជាទ្រង់មានព្រះបន្ទូលថា បើអ្នកបរិភោគយើងហើយ ធ្វើម្តេចយើងនឹងបានស្តាប់ធមិអ្នក ដែលយើងស៊ូលះបង់ជីវិត និងរាជសម្បត្តិចូលមកក្នុងព្រៃនេះ ក៏ព្រោះតែចង់ស្តាប់ធមិប៉ុណ្ណោះឯង ។ ឥន្ទយក្ខនិយាយថា បើដូច្នោះសូមមហារាជឡើងទៅលើកំពូលភ្នំដែលខ្ពស់នេះចុះ កាលបើឡើងទៅដល់កំពូលភ្នំហើយលោតចុះមកឱ្យចំមាត់យើងៗ នឹងសំដែងថ្វាយឱ្យបានប្រយោជន៍ទាំងអស់គ្នា គឺមហារាជក៏បានស្តាប់ធមិ ខ្ញុំព្រះអង្គក៏បានបរិភោគមហារាជ ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យឥន្ទយក្ខហើយ ទ្រង់ព្រះចិន្តាថា ពាក្យដែលយក្ខនិយាយនេះគួរហើយ ថ្ងៃនេះបំណងរបស់អញសម្រេចហើយ អញត្រូវតែលះបង់ជីវិតដើម្បីស្តាប់ធមិចុះ. ទើបទ្រង់មានព្រះបន្ទូលទៅកាន់ឥន្ទយក្ខថា ម្នាលសម្លាញ់ពាក្យអ្នកនិយាយអម្បាញ់មិញនេះប្រសើរណាស់ អ្នកជាបុគ្គលមានឧបការៈច្រើនដល់យើងពិត ព្រោះហេតុនោះយើងធ្វើតាមពាក្យរបស់អ្នក សូមអ្នកកុំមានវង្វេងសចិត្តឡើយ ចាំសំដែងធមិឱ្យយើងស្តាប់ចុះ ។

លុះមានព្រះបន្ទូលដូច្នេះហើយ ក៏ឡើងទៅឈរលើកកំពូលភ្នំ ហើយបន្លឺ

ព្រះសូរសីហនាទថា " ថ្ងៃនេះអញបានបូជាជីវិតផង រាជសម្បត្តិផង ចំពោះព្រះធម៌ទេសនា" បពិត្រមហាយក្ខ យើងមានសេចក្ដីត្រេកអរយ៉ាងក្រៃលែងចំពោះធម៌ទេសនារបស់អ្នក សូមអ្នកសំដែងធម៌ចុះ ទ្រង់មានព្រះបន្ទូលហើយ ក៏លោតចុះទៅសំដៅមាត់យក្ខដែលហាចាំពីក្រោម ។ ខណៈនោះឥន្ទយក្ខ ក៏ក្លាយខ្លួនជាព្រះឥន្ទវិញភ្លាមហើយបីពព្រះរាជាហោះទៅស្ថានត្រៃត្រឹង្សឱ្យគង់លើថ្មបណ្ឌុកម្ពល បូជាដោយគ្រឿងសក្ការៈទិព្វច្រើនជាអនេក ហើយថ្វាយដំណឹងដល់ព្រះរាជាថា សូមមហារាជប្រុងស្ដាប់ធម៌ចុះ ខ្ញុំនឹងសំដែងធម៌ដែលខ្ញុំបានស្ដាប់ពីសំណាក់ព្រះសម្ពុទ្ធអំពីបុរាណមកថាៈ

**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**
**ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។**

ព្រះបាទធម្មសោណ្ឌកៈរាជ កាលបើបានស្ដាប់នូវព្រះធម៌ទេសនារបស់ព្រះឥន្ទហើយមានសេចក្ដីរីករាយយ៉ាងក្រៃលែង ហាក់ដូចបានស្ដាប់អំពីសំណាក់ព្រះសម្ពុទ្ធ ។ បន្ទាប់អំពីធម្មទេសនានោះមក ព្រះឥន្ទបានសំដែងប្រាប់នូវសេចក្ដីសុខក្នុងទេវលោកសព្វគ្រប់ហើយ ក៏នាំព្រះរាជាត្រឡប់មកស្ថានមនុស្សលោកឱ្យសោយរាជសម្បត្តិដូចដើមវិញ ។

ព្រះបាទធម្មសោណ្ឌកៈរាជក្នុងកាលនោះ គឺព្រះសម្ពុទ្ធបរមគ្រូយើងនេះឯង ។

❊❊✳❊❊

## អានិសង្សបុណ្យ ៥ យ៉ាង គឺៈ

**១. តិក្ខបញ្ញាវិសារទៈ** មានប្រាជ្ញាក្លៀវក្លាមុះមុត.

**២. សុវណ្ណតា** មានពណ៌សម្បុរល្អ.

**៣. សុរូបតា** មានរូបល្អ.

**៤. សុសណ្ឋានា** មានទ្រង់ទ្រាយល្អ.

**៥. ចក្កវត្តិរាជៈហោតិ** នឹងបានទៅជាស្ដេចចក្រពត្តិ ក្នុងជាតិណាមួយពុំខានឡើយ ។

## អានិសង្សបុណ្យ ជាបុគ្គលាធិដ្ឋាន

## រឿងនាងរោហិណី

(បុណ្យរមែងសម្រេចតាមបំណងអ្នកៈធ្វើ ដែលបានតាំងប្រាថ្នា)

មានសេចក្ដីដំណាលថា ព្រះអនុរុទ្ធដ៏មានអាយុបាននាំភិក្ខុជាបរិវារ ៥០០ រូប និមន្តទៅកាន់កបិលវត្ថុបុរី ។ ពេលនោះញាតិវង្សជ្រាបថា ព្រះថេរៈនិមន្តមកក៏នាំគ្នាថ្វាយបង្គំ បាត់តែនាងរោហិណីជាប្អូនបង្កើតមិនឃើញមកថ្វាយបង្គំ។ ព្រះថេរៈក៏សួរដំណឹងបានជ្រាប ដោយញាតិវង្សប្រាប់ថា នាងមានសេចក្ដីអៀនខ្មាស់ជាពន់ពេក ព្រោះកើតរោគសើស្បែក (ស្រេង) បានជាមិនមក ។ ព្រះថេរៈក៏បង្គាប់ឱ្យគេហៅមក. កាលបើនាងមកដល់ហើយថ្វាយបង្គំដោយគោរព លោកសួរថា ហេតុអ្វីបានជានាងមិនមក? នាងទូលតាមអាការៈនៃ

សេចក្ដីអៀនខ្មាស ចំពោះព្រះថេរៈ។ ក៏សួរបន្តទៅទៀតថា ចុះក្រែងនាងមិនធ្វើបុណ្យទេឬ? ឱ្យខ្ញុំព្រះករុណាធ្វើបុណ្យអ្វី? ចូរនាងសាងអាសនៈសាលាមួយទៅ។ នាងថាចុះខ្ញុំព្រះករុណាបានអ្វីធ្វើ ? ព្រះថេរៈសួរថា ចុះនាងមានបសាធនភណ្ឌដែរឬទេ? នាងឆ្លើយថាមាន ។ បើដូច្នោះចូរនាងលក់របស់នោះ យកប្រាក់មកសង់សាលាចុះ នាងសួរថា នរណាគេជួយសង់ឱ្យខ្ញុំព្រះករុណា ? ព្រះថេរៈក៏និយាយអង្វរក្រុមញាតិដែលនៅអង្គុយជិតថា សូមឱ្យជួយធ្វើអាសនៈសាលានាងរោហិណីផង អាត្មានឹងជួយឧបត្ថម្ភក្នុងកិច្ចកសាងនេះដែរ ។ ឯក្រុមញាតិគេមានសេចក្ដីអាណិតនាងរោហិណីណាស់ ទឹងគោរពតាមពាក្យអង្វរនៃព្រះថេរៈផង ក៏ជួយធ្វើដោយស្មោះស្ម័គ្រ ។ ព្រះថេរៈបានឱ្យគេទៅនាំទិព្វសម្ភារៈសម្រាប់ការកសាងនេះ ហើយបង្គាប់ឱ្យធ្វើសាលានោះពីរជាន់ និងបង្គាប់ឱ្យនាងរោហិណីជាប្អូន ថែទាំបោសសំអាតសាលាចាប់តាំងពីពេលក្រាលរនាបរួចព្រមទាំងឱ្យតាក់តែងអាសនៈ និងដងទឹកតម្កល់ទុកសម្រាប់ប្រើប្រាស់លើសាលាជានិរន្តរ៍ កុំឱ្យអាក់ខានមួយពេលណាឡើយ ។ នាងរោហិណី ក៏ទទួលធ្វើតាមបង្គាប់បងឥតមានខ្ចោះ ត្រាតែដល់រោគសើស្បែកសះស្បើយស្រពោនថយចុះបន្តិចម្ដង។ ដោយអំណាចនៃបុញ្ញកម្មដែលនាងបានបោសសំអាតសាលាជាដើម។ ថ្ងៃមួយនាងបានចាត់ចែងទានដ៏ថ្លៃថ្លាប្រគេនដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន លើអាសនៈសាលានាង ។ លុះព្រះបរមគ្រូសម្រេចភត្តកិច្ចហើយ ទ្រង់ត្រាស់សួរព្រះអនុរុទ្ធថា ហៃអនុរុទ្ធ អ្នកណាជាម្ចាស់ទាននេះ ព្រះអនុរុទ្ធទូលថា បពិត្រព្រះមានជោគនាងរោហិណីប្អូនស្រីខ្ញុំព្រះអង្គជាម្ចាស់ទាននេះ ។

ចុះនាងនៅឯណា? បពិត្រព្រះអង្គ នាងនៅក្នុងផ្ទះ ។

ព្រះអង្គក៏ត្រាស់ឱ្យហៅនាងមកតែមិនមក. ទើបទ្រង់ត្រាស់ហៅផ្ទាល់ព្រះអង្គឯង ត្រាតែនាងមក ក៏ទ្រង់សរសើរថា នាងរោហិណី ! ហេតុអ្វីបានជានាងមិនមក ? នាងទូលថា ខ្ញុំព្រះអង្គមានសេចក្តីអៀនខ្មាស់ណាស់ ព្រោះតែកើតរោគសើស្បែក ។ រោគនេះកើតដល់នាង តើនាងដឹងថាកើតឡើងដោយហេតុអ្វី? នាងទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនដឹងសោះ ។ ព្រះអង្គត្រាស់ថា រោគសើស្បែកកើតឡើងដោយសេចក្តីក្រោធ ។

នាងក៏សូរបុព្វកម្មដែលខ្លួនកសាងពីជាតិមុន ចំពោះព្រះអង្គ១ ត្រាស់ថាៈ

ក្នុងកាលពីព្រេងព្រឹទ្ធយូរយាណាស់ហើយ នាងបានជាអគ្គមហេសីនៃព្រះចៅក្រុងពារាណសី ។ ក្នុងចំណោមស្រីស្នំស្រីង្គារទាំងអស់ជាព្រះរាជបរិវារមានស្រីរបាំម្នាក់ មានរូបល្អស្រស់បស់ជាទីគាប់ព្រះទ័យព្រះរាជា ទ្រង់បានរួមរស់មេត្រីសេចក្តីស្នេហាតាមភាពនៃបុថុជ្ជនជានិច្ចជាកាល ឥតមានប្រែព្រះទ័យស្នេហាលើរូបនាងជាអគ្គមហេសី ឬស្រីស្នំឯទៀតឡើយ ម្លោះហើយអគ្គមហេសីក៏មានសេចក្តីប្រចណ្ឌច្រណែនឈ្នានិះចងគំនុំនឹងស្រីរបាំនោះថា អញនឹងធ្វើហងឱ្យមានសេចក្តីទុក្ខលំបាកជាមិនខាន លុះគិតដូច្នេះ ក៏បង្គាប់ឱ្យស្រីស្និទ្ធស្នាលមួយរូបយកខ្ញែមក ទើបនាងលបគោះលំអិតខ្ញែដាក់លើដំណេកនាងរបាំនោះ ពេលនោះហើយ ក៏ចូលទៅរកនាងរបាំប្រឡែងគ្នាលេង ធ្វើហាក់ដូចជាមានសេចក្តីរាប់រកណាស់ ហើយគោះលំអិតខ្ញែដាក់លើសរីរៈនាងទៀត ។ នាងរបាំក៏ខ្វាខ្វាំសរីរៈនោះដរាបដល់ដាលឡើងជាពកតូចពកធំ. នាងរត់ទៅប្រះខ្លួនលើដំណេក

ក៏ស្រាប់តែរមាស់ជាក្រៃលែង ដោយមានលំអិតខ្ទៃនៅលើទីនោះឯង ។ អគ្គមហេសីក្នុងកាលនោះបានមកកើតជានាង (រោហិណី) ហ្នឹង។ លុះសំដែងបុព្វកម្មចប់ហើយ ព្រះសម្ពុទ្ធទ្រង់មានពុទ្ធដីកាតទៅទៀតថា ម្នាលនាងរោហិណី នាងបានធ្វើកម្មយ៉ាងនេះឯង ព្រោះហេតុនោះ សេចក្តីក្រោធសូម្បីតែបន្តិចបន្តួចក្តី សេចក្តីប្រណែនក្តី នាងមិនគួរធ្វើទេ ។ ចប់ព្រះធម៌ទេសនាកាលណា នាងរោហិណីក៏បានសម្រេចសោតាបត្តិផលក្នុងពេលនោះ ទឹងមានសរីរៈស្អាតបាតសមរម្យល្អដូចជាមាសទឹកដប់ លុះអស់អាយុពីលោកនេះទៅ បានទៅកើតក្នុងឋានតាវតឹង្សជាចន្លោះដែនដីទេវបុត្រទាំង ៤ អង្គ មានរូបរាងល្អឆ្នើម គួរជាទីគាប់ចិត្តនៃទេវបុត្រទាំងនោះជាពន់ពេក ។ ព្រោះតែរូបនាងល្អយ៉ាងនេះ បានជា (ទេវបុត្រទាំង ៤ កើតស្នេហា ជជែកតវ៉ាដណ្តើមគ្នា ខំឈ្លោះប្រកែកបែកសមគ្គា ប្រាថ្នាជាយារៀង១ អង្គ ។ រូបនាងនេះឯងខែងអស្ចារ្យ នាំឱ្យទេព្តាកើតសៅហ្មង សួរសព្ទសំឡេងលាន់អឹងកង ព្រោះតែចំណងនៃតណ្ហា ។ ទេវបុត្រមួយអង្គថាបានខ្ញុំ ព្រោះនាងកើតចំខ័ណ្ឌសីមា ស្ថិតលើដីខ្ញុំជាក់ណាស់ណា មិនត្រូវតវ៉ាដណ្តើមអី ។ ទេវបុត្រមួយអង្គឆ្លើយឡើងថា អែយ៉ាគាត់នេះវង្វេងដីកំពុងភ្លឹកចិត្តព្រោះរូបស្រី ហើយលែងស្គាល់ដីគេដីឯង ។ ទេវបុត្រមួយទៀតក៏វាចា នៃលោកទេព្តាកុំខែងរែង នាងនេះគួព្រេងខ្ញុំជាក់ស្តែង ព្រោះកើតត្រង់ចែងដីខ្ញុំណា ទេវបុត្រមួយទៀតក៏ឆ្មៀតប្រឹងក្រោកឡើងសន្ធឹងក្តាងវាចា ថានាងនេះពិតគួស្នេហា មិនត្រូវការបានអស់លោកអី ។

ដល់រឿងជជែកមិនដាច់ស្រេច នាំគ្នាសម្រេចទៅតក្តី ដល់ឋានព្រះឥន្ទ-

កោសីយ ឱ្យវិនិច្ឆ័យរកយុត្តិធម៌ ។ ពាក្យកាព្យ ។ល។

ទេព្ដាទាំង ៤ អង្គក៏នាំនាងរោហិណី ស្រ្ដីល្អឆើតនេះ ទៅប្ដឹងដល់សម្ដេចឥន្ទ្រាធិរាជ ឱ្យរកយុត្តិធម៌ឱ្យ ។ អកុសលទៅទៀត ! សម្ដេចឥន្ទ្រាធិរាជ គ្រាន់តែទតព្រះនេត្រចំរូបនាងរោហិណីភ្លាម ក៏មានគ្រឿងចក្រដើរបែបមិនស្រួលតែម្ដង ហួសពីទេវបុត្រទាំង ៤ នោះទៅទៀត ។ ទើបទ្រង់ត្រាស់សួរថាអ្នកទាំងឡាយមកនេះមានការអ្វី? ទេវបុត្រក៏ក្រាបបង្គំទូលពីរឿងនាងរោហិណីថាខ្លួនមានសេចក្ដីស្រឡាញ់គ្រប់ៗ គ្នា ។

ព្រះឥន្ទ្រាត្រាស់សួរទេវបុត្រទាំង ៤ ថា ចិត្តអ្នករាល់គ្នាតាំងពីឃើញរូបនាងរោហិណី តើមានសេចក្ដីស្រឡាញ់យ៉ាងណាខ្លះ? ចូរអ្នករ៉ាយរ៉ាប់សេចក្ដីមកមើល ! ។

ទេវបុត្រទី ១ ទូលថាចិត្តខ្ញុំព្រះអង្គនៅមិនស្ងៀមសោះ តាំងពីឃើញរូបនាងកាលណា ចេះតែរំភើបញាប់ញ័រច្រូលច្របល់ភ័យអរៗ ជានិច្ចហាក់បីដូចជាស្គរជ័យដែលនៅកណ្ដាលរឿណរង្គ នៃសមរភូមិដូច្នោះ ។

ទេវបុត្រទី ២ ចិត្តខ្ញុំព្រះអង្គស្រឡាញ់នាងរោហិណីណាស់ តែងតែហូរចេញមកពីបេះដូងដ៏ក្រៀមក្រំ គ្របដណ្ដប់លើរូបនាង មិនដែលដាច់ពេលណាទេ ហាក់ដូចជាទឹកឈ្មេរដែលហូរចុះពីលើកំពូលភ្នំដូច្នោះ ។

ទេវបុត្រទី ៣ ទូលថា ចិត្តខ្ញុំស្រឡាញ់នាងរោហិណីខ្លាំងហួសនិស្ស័យណាស់ព្រះអង្គ សូម្បីតែបាត់មុខនាងមួយនាទីសឹងមិនបាន. ពិសេសទៅទៀតចក្ខុទាំងគូរបស់ខ្ញុំដែលសំឡឹងនាងម្ដងៗ ស្ទើរតែលៀនចេញមកដូចភ្នែកក្ដាម

ទៅហើយ ។

ទេវបុត្រទី ៤ ទូលថា បពិត្រព្រះឧប្បត្តិទេវាវង្ស! ចិត្តខ្ញុំព្រះអង្គ តាំងពីឃើញនាងរោហិណីកាលណា មិនបាននៅហ្នឹង ដូចធម្មតាទេ ចេះតែស្ទុះឆ្វេឆ្វា ចុះឡើងៗ គ្មានពេលណាសម្រាកសោះ ហាក់ដូចជាទង់ដែលបុគ្គលលើកឡើងលើកំពូលចេតិយ ហើយត្រូវជំនោរខ្យល់បោកបក់មក ទង់នោះតែងតែមានកន្ទុយបក់រវិចគ្មានឈប់សម្រាកយ៉ាងណា ! ចិត្តខ្ញុំដែលស្រឡាញ់នាងរោហិណីក៏ដូច្នោះដែរ ។

សម្ដេចអមរិន្ទ្រាធិរាជទ្រង់ព្រះសណ្ដាប់សេចក្ដីរាយការណ៍នៃសេចក្ដីស្រឡាញ់ចំពោះលើរូបនាងរោហិណី របស់ទេវបុត្រទាំង ៤ អង្គនោះចប់ហើយ មានបន្ទូលថា ចិត្តអ្នករាល់គ្នាដែលស្រឡាញ់នាងរោហិណីនេះ បើតាមខ្ញុំយល់ថា នៅអត់ទ្រាំបាន មិនទាន់ជាខ្លាំងណាស់ណាទេ. ឯចិត្តខ្ញុំវិញ ចាប់តាំងពីឃើញរូបនាងនេះ ក៏មានសេចក្ដីស្រឡាញ់ជាអស្ចារ្យទាំងបានប្ដេជ្ញាចិត្តថា បើមិនបាននាងរោហិណី ធ្វើជាអគ្គមហេសីទេ មុខតែស្លាប់ក្នុងទីនេះជាមិនខាន. បើបានធ្វើជាអគ្គមហេសី ទើបមានជីវិតរស់នៅបានឃើញមុខអ្នករាល់គ្នាតទៅទៀត ។

ទេវបុត្រទាំងនោះ បានឮបន្ទូលតបនៃសក្កទេវរាជហើយ ក៏ព្រមព្រៀងគ្នាលើកនាងរោហិណីថ្វាយជារង្វាន់ដ៏គាប់ព្រះទ័យ ដល់ព្រះអង្គ ដើម្បីកុំឱ្យសោយព្រះទីវង្គត ។ នាងរោហិណីបានឡើងឋានន្តរៈជាអគ្គមហេសីជាទីពេញព្រះទ័យនៃព្រះឥន្ទជាពន់ពេក ទ្រង់តែងមានសេចក្ដីប្រោសប្រាណ ចំពោះពាក្យបបួលទៅលេងក្នុងទីណាៗ របស់នាងជាធម្មតា មិនដែលហ៊ានហាមឃាត់ ឬ

ប្រកែកនឹងពាក្យនោះដល់ម្តងណាឡើយ ។

ព្រោះហេតុនោះបានជាលោកសំដែងថា បុណ្យរមែងឱ្យសម្រេចប្រយោជន៍តាមសេចក្តីប្រាថ្នាគ្រប់កាលវេលាទាំងពួង ដូចរឿងនាងរោហិណីនេះជាតួយ៉ាង ។

## អានិសង្សកឋិន៥យ៉ាង របស់ភិក្ខុ

**១- អនាមន្តចារោ, ២- អសមាទានចារោ, ៣- គណភោជនំ, ៤- យាវទត្ថចីវរំ, ៥- យោច តត្ថចីវរុប្បាទោ សោ នេសំ ភវិស្សតិ ។**

ទី ១- ឱ្យរួចចាកអាបត្តិក្នុងចារិត្តសិក្ខាបទទី ៦ ក្នុងអចេលកវគ្គ (សុទ្ធិកបាចិត្តិយ) ។

ទី ២- ឱ្យរួចចាកអាបត្តិក្នុងទុតិយកឋិនសិក្ខាបទទី ២ ក្នុងចីវរវគ្គ (និស្សគ្គិយបាចិត្តិយ) ។

ទី ៣- ឱ្យរួចចាកអាបត្តិក្នុងគណៈភោជនទី ២ ក្នុងភោជនវគ្គ (សុទ្ធិកបាចិត្តិយ) ។

ទី ៤- ឱ្យរួចចាកអាបត្តិក្នុងបឋមសិក្ខាបទទី ១ ក្នុងចីវរវគ្គ (និស្សគ្គិយបាចិត្តិយ) ។

ទី ៥- ឱ្យរួចចាកអាបត្តិ ឱ្យមានសិទ្ធិទទួលចំណែកគណៈភោជនលាភដែលកើតក្នុង "អាវាស" នោះៗ ។

# កឋិនទាន

ក្នុងទំព័រសៀវភៅនេះ ខ្ញុំកូណាខ្ញុំបាទ សូមលើកយកពាក្យថា **កឋិននេះ** មកនិយាយដោយសង្ខេបដូចតទៅនេះ :

ពាក្យថាកឋិនសព្ទនេះ បើតាមអដ្ឋកថា លោកសំដៅយកពុទ្ធដីកា ដែលព្រះសម្ពុទ្ធទ្រង់សំដែងបញ្ញត្តិទុកថា ការប្រជុំរូបរួមរូបធម៌និងនាមធម៌ ហៅថា កឋិន១ នេះលោកពន្យល់ថា មកពីកឋធាតុដែលប្រែថា ប្រព្រឹត្តទៅក្នុងអត្ថពីរយ៉ាងគឺ:

១- ប្រែថា រស់នៅបានដោយកម្រ. សមដូចវិគ្គហៈថា **កឋតិ កិច្ឆេន ជីវតីតិ > កឋិនោ** សភាវៈឯណារស់នៅបានដោយកម្រ សភាវៈនោះ ហៅថា កឋិន. ព្រោះលោកប្រៀបដូចជាឈើស្ងួត ដែលបុគ្គលកាត់ចេញចាកដើម ហើយយកទៅបោះភ្ជាប់នឹងផែនដី រមែងដុះលូតលាស់ឬរស់នៅបានដោយកម្រយ៉ាងណា ! ឯកិច្ចដែលនឹងកើតឡើង ឬតាំងឡើងជាកឋិនពេញទី គឺបានដោយកម្រពន់ពេកណាស់ ក៏យ៉ាងនោះដែរ ។

២- ប្រែថា ពោលសរសើរ ព្រោះចីវរទានដែលយើងបានសាងជាកឋិននោះ ជាទានវិសេសជាងទានដទៃៗ ដែលព្រះអរិយទាំងឡាយមានព្រះសម្ពុទ្ធជាប្រធានតែងពោលសរសើរថា ជាទានវិសេសអាចរួបរួម ឬសង្គ្រោះទុកនូវអានិសង្ស ៥ យ៉ាងរបស់ភិក្ខុអ្នកក្រាលគ្រងមិនឱ្យទៅក្នុងទីដទៃបាន សមដូចវិគ្គហៈថា :

**បញ្ច អានិសំសេ អញ្ញត្ថ គន្ត្វំ អនត្វា គឋតិ សន្តណ្ណាតិត្តិ >**

**គឋិនំ** ធម្មជាតិឯណាក្រៀកទុក ឬសង្គ្រោះនូវអានិសង្សទាំង ៥ មិនឱ្យទៅក្នុងទីដទៃបាន ធម្មជាតិនោះឈ្មោះថាកឋិន កឋិននេះអាចឱ្យសម្រេចផលដល់បុគ្គលទាំងពីរផ្នែក. គឺទាយកអ្នកឱ្យក៏ត្រូវបានអានិសង្សច្រើន ត្រូវទទួលផលប្រយោជន៍ក្នុងកាលអនាគតដែលខ្លួនត្រូវបាន. មានការទទួលនូវសម្បត្តិក្នុងឋានទេវលោកជាដើម ចំណែកបដិគ្គាហកៈ គឺភិក្ខុអ្នកទទួលក្រាលគ្រងកឋិននិងបុគ្គលឬគណៈ ព្រមទាំងសង្ឃដែលបានអនុមោទនា ក៏បានសម្រេចនូវអានិសង្សទាំង ៥ ប្រការពេញលេញគ្រប់គ្រាន់ ដរាបដល់រយៈកាលនៃកឋិនខេត្ត ។

មូលហេតុដែលនាំឱ្យកើតគុឋិនទាននេះ ដោយមាននិទានថា:

សម័យនោះ នៅក្នុងរវាងមជ្ឈិមពោធិកាល ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីសាងថ្វាយទៀបក្រុងសាវត្ថី គ្រានោះមានភិក្ខុ ៣០ អង្គឈ្មោះថា ភទ្ទវគ្គិយត្ថេរក្នុងដែនបាថេយ្យ ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ។ល។ ក៏នាំគ្នាចេញអំពីទីនោះមកកាន់ក្រុងសាវត្ថី ដើម្បីគាល់បំរើព្រះមានព្រះភាគ ទើបមកដល់ពាក់កណ្តាលផ្លូវ ចួនជាដល់ថ្ងៃចូលព្រះវស្សា នឹងស្រូតមកទៀតមិនទាន់ ក៏នាំគ្នាស្វែងរកសេនាសនៈនៅចាំវស្សា ទៀបក្រុងសាកេត នាពាក់កណ្តាលផ្លូវនោះទៅ ភិក្ខុទាំងនោះមានសេចក្តីអផ្សុកជាខ្លាំងដោយគិតឃើញថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងទីជិតចម្ងាយ ៦ យោជន៍ទៀតសោះ មិនសមបើយើងទាំងស្ទុនដំណើរមិនបានទៅគាល់បំរើព្រះអង្គ! លុះដល់ថ្ងៃចេញវស្សាបវរណាស្រេចហើយ លោកក៏នាំគ្នា

ស្រូតចេញអំពីទីនោះមកទៀត ទទួលរដូវនោះនៅមានភ្លៀងរលឹមជោកជាំនៅឡើយ តាមផ្លូវដែលទៅមកពោរពាសដោយទឹកនិងភក់រអិលប៉ប៉ិចប៉ប៉ាច់ ។ល។ លុះដល់ក្រុងសាវត្ថីហើយ ចូលទៅកាន់វត្តជេតពន ដែលព្រះមានព្រះភាគទ្រង់គង់នៅ ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចស្រេចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ លំដាប់នោះព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលរាក់ទាក់ទៅរកភិក្ខុទាំងនោះថា: ម្នាលភិក្ខុទាំងឡាយ ! សរីរៈយន្តរបស់អ្នកទាំងឡាយ ល្មមអត់សង្កត់បានឬទេ? ល្មមប្រព្រឹត្តបានឬទេ? អ្នកទាំងឡាយមានសេចក្ដីព្រមព្រៀងស្មោះស្មើឥតមានវិវាទទាស់ទែងគ្នាឬទេ ? អ្នកទាំងឡាយនៅចាំវស្សាសោត ស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេឬ? ភិក្ខុទាំងឡាយនោះ ក្រាបបង្គំទូលតាមដំណើរដូច្នោះរួចហើយ ក៏ក្រាបបង្គំទូលអំពីសេចក្ដីលំបាករបស់ខ្លួន ដែលមកតាមផ្លូវដោយសព្វគ្រប់តាមដំណើរ ។

លំដាប់នោះព្រះមានព្រះភាគ ទ្រង់សំដែងនូវធម្មីកថា ប្រារព្ធអំពីសង្សារវដ្ដមិនមានទីបំផុតប្រោសប្រទានភិក្ខុទាំងនោះ. លុះចប់ធមិហើយ ភិក្ខុទាំងនោះ ក៏បានជាព្រះអរហន្តទាំងអស់អង្គ. ហើយនាំគ្នាហោះតាមអាកាសទៅកាន់ទីលំនៅរបស់ខ្លួនអស់ទៅ ។

បន្ទាប់ពីនោះមក ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា បើប្រសិនជាតថាគតបានតែងតាំងកឋិនត្ថារកិច្ចទុកអំពីគ្រាមុន ម្ល៉េះសមភិក្ខុទាំងនោះនឹងបានលះចីវរមួយទុកនៅទីកន្លែង ជាប់មកតែស្បង់ចីពរប៉ុណ្ណោះ នឹងមានអត្តភាពស្រាលមិនលំបាកយ៉ាងនេះសោះឡើយ ហើយកឋិនត្ថារកិច្ចនេះសោត

ព្រះពុទ្ធទាំងឡាយរាល់ព្រះអង្គ  ក៏តែងទ្រង់អនុញ្ញាតទុកដល់សាវកពុំដែលលះបង់ផង  ព្រះសម្ពុទ្ធទ្រង់ព្រះតម្រិះដូច្នេះហើយ  ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់អនុញ្ញាត កឋិនត្ថារកិច្ចនេះ ដោយព្រះពុទ្ធដីកាថា:

**អនុជានាមិ ភិក្ខវេ វស្សំ  វុដ្ឋានំ ភិក្ខូនំ កឋិនំ**
**អត្ថរិតុំ អត្ថតកឋិនានំ វោ ភិក្ខវេ  បញ្ច កប្បិស្សន្តិ ។**

ម្នាលភិក្ខុទាំងឡាយ  តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយ  ដែលបាននៅចាំវស្សារួចហើយទទួលក្រាលកឋិន ។ ម្នាលភិក្ខុទាំងឡាយ  កាលបើភិក្ខុទាំងឡាយបានក្រាលកឋិនហើយនឹងបានសម្រេចអានិសង្ស ៥ ប្រការ ។ (ដូចមាននៅទំព័រខាងដើមស្រាប់) ។

## កឋិនទានានិសំសកថា

**យេ ជនា សុខមិច្ឆន្តា  ទត្វាន កឋិនចីវរំ**
**តេបិ ទុក្ខា បមុញ្ចន្តិ  តុដ្ឋា ទេវេសុ មនុស្សេសុ**
**នរកាទីនំ ន ជាយន្តិ  កឋិនទានស្សិទំ ផលំ**
**ចទេវលោកេ ចិរំ តុដ្ឋា  ទិព្វសម្បត្តិ តតោ**
**ចវិត្វា មនុស្សលោកេ  រាជា ហោន្តិ មហព្វលា**
**សត្តរតនសម្បន្នា ចតុទីបេសុ ឥស្សរា តេ ជនា**
**សំសរន្តាបិ អបាយេ ន  គមិស្សន្តិ ទ្វេ កុលេ**
**ឧបបជ្ជន្តិ ខត្តិយេ ចាបិ  ព្រាហ្មណោ ហីនេ កុលេ**

## ន ជរា យន្តិ កឋិនទានស្សិទំ ផលំ ។

ជនទាំងឡាយឯណាប្រាថ្នានូវសេចក្ដីសុខ ឱ្យនូវចីវរដើម្បីកឋិនទាន ជនទាំងឡាយនោះឯង រមែងរួចចាកទុក្ខក្នុងទេវតា និងមនុស្សទាំងឡាយ នឹងមិនកើតក្នុងអបាយទាំងឡាយ មាននរកជាដើម. នេះជាផលរបស់កឋិនទាន ជនទាំងឡាយនោះ នឹងបានសោយនូវសម្បត្តិដ៏ជាទិព្វ ក្នុងទេវលោកទាំង ៦ ជាន់ កាលដ៏យូរអង្វែង ។

លុះច្យុតអំពីទេវលោកនោះមក នឹងបានជាស្ដេចក្នុងមនុស្សលោកនេះ. ជាស្ដេចមានកម្លាំងច្រើន បរិបូណ៌ដោយរតនៈ ៧ ប្រការ នឹងបានជាធំក្នុងទ្វីបទាំង ៤ កាលបើនៅអន្ទោលទៅមកក្នុងមនុស្សលោកនេះ នឹងមិនបានទៅក្នុងអបាយ រមែងកើតក្នុងត្រកូលទាំងពីរគឺ: ខត្តិយត្រកូល ១. ព្រាហ្មណត្រកូល ១. មិនកើតក្នុងត្រកូលថោកទាបឡើយ. នេះជាផលរបស់កឋិនទានដែលជនទាំងឡាយបានកសាងហើយ ។

## អានិសង្សខន្តី ៥ យ៉ាងគឺ:

១~ បិយោមនាបោ នឹងបានជាទីស្រឡាញ់រាប់អាន របស់ទេវតា និងមនុស្សទាំងឡាយ.

២~ នវេរពហុលោ មិនចំរើនដោយពៀរវេរា.

៣~ នវជ្ជពហុលោ នឹងមិនចំរើនទៅដោយទោសៈ.

៤~ អសម្មុឡ្ហោ នឹងមានស្មារតីមិនវង្វេងភ្លេចក្នុងវេលាស្លាប់.

៥~ សុគតិ ស្លាប់ហើយនឹងទៅកើតក្នុងស្ថានសួគ៌ ។

# អានិសង្សខន្តី

ជាបុគ្គលាធិដ្ឋាន

---

## រឿងកង្កែបស្តាប់ធម៌

កាលព្រះសម្ពុទ្ធទ្រង់គង់ធរមាននៅឡើយ ពេលមួយព្រះអង្គទ្រង់ប្រទានធម៌ទេសនា ដល់បរិសទ្យអ្នកនៅក្នុងនគរចម្បា ក្បែរមាត់ស្រះបោក្ខរណីឈ្មោះគគ្គរា ។

គ្រានោះមានសត្វកង្កែបមួយកំពុងសម្ងំស្តាប់ធម៌ទេសនា ស្រាប់តែមានក្មេងគង្វាលគោម្នាក់ ដើរមកឈរច្រត់ដំបងសង្កត់លើក្បាល. កង្កែបនោះខំធន់ទ្រាំនឹងជម្ងឺប្រើងតែស្តាប់ធម៌ មិនលះបង់សព្ទព្រះសទ្ធម្ម ក៏ធ្វើមរណកាលក្នុងខណៈនោះទៅ ទៅកើតក្នុងស្ថានតាវតឹង្ស បានឈ្មោះថា "មណ្ឌុកទេវបុត្រ" នៅក្នុងវិមានមាសកំពស់ ១២ យោជន៍ ហាក់ដូចជាភ្ញាក់ពីដេក ហើយស្រាប់តែឃើញពួកស្រីទេពអប្សរ ចោមរោមជាបរិវារ ក៏នឹកថា យីអើ ! គួរឱ្យឆ្ងល់ពេកណាស់ ហេតុអ្វីអេះ ! អញលោតែមកប្រតិស្ឋានក្នុងទីនេះ ! រំពឹងទៅឃើញបុញ្ញកម្មដែលខ្លួនខំអត់ទ្រាំនឹងជម្ងឺប្រើងផ្ចង់ស្មារតីមិនឱ្យឃ្លៀងឃ្លាតពីព្រះសទ្ធម្មទេសនារបស់ព្រះសម្ពុទ្ធ ទើបហោះចុះពីទេវលោកព្រមទាំងវិមាន មកថ្វាយបង្គំព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

គ្រានោះព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធតម្រាស់សួរថា:

**កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ**

**អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា ។**

អ្នកណាហ្ន៎ ! មានឫទ្ធិ មានយសរុងរឿង មានរស្មីចែងចាំងញ៉ាំងទិសទាំងពួងឱ្យភ្លឺថ្លា មកសំពះបាទាតថាគត ? ។ ទេវបុត្រក្រាបទូលថា:

**មណ្ឌូកោហំ បុរេ អាសឹ ឧទកេ វារិគោចរោ**

**តវ ធម្មំ សុណន្តស្ស អវធី វច្ឆបាលកោ ។**

ខ្ញុំព្រះអង្គ កាលពីដើមឡើយជាសត្វកង្កែប នៅអាស្រ័យក្នុងទឹកមានវារីជាទីគោចរ កាលកំពុងស្តាប់ធម៌ព្រះអង្គ អ្នកគង្វាលគោសម្លាប់ខ្ញុំព្រះអង្គ ។

ព្រះសម្ពុទ្ធ ទ្រង់ព្រះសណ្តាប់ហើយ ក៏ទ្រង់ប្រទានធម៌ទេសនាសត្វទាំងឡាយ បានលុះមគ្គាភិសម័យ ចំនួន ៨ ម៉ឺន ៤ ពាន់នាក់ ។ ឯទេវបុត្រនោះ បានលុះដល់សោតាបត្តិផល ក៏ហោះទៅកាន់ទេវលោកវិញ ។

រឿងនេះបញ្ជាក់ឱ្យឃើញថា ខន្តីសេចក្តីអត់ធន់ចំពោះអារម្មណ៍មិនសមបំណង ឬចំពោះគ្រោះកាចណាមួយមកបៀតបៀន ក្នុងពេលដែលយើងកំពុងតែតាំងចិត្តសាងសន្សំនូវសេចក្តីល្អ. យើងគង់បានទទួលនូវផលល្អសមតាមបំណងប្រាថ្នាពុំខានឡើយ. ដូចសត្វកង្កែបអត់ធន់នឹងជម្ងឺដែលអ្នកគង្វាលគោយកដំបងច្រត់លើក្បាល ក្នុងពេលដែលកំពុងតែស្តាប់ធម៌ទេសនាព្រះសម្ពុទ្ធ ទោះបីឈឺយ៉ាងណា ក៏កង្កែបអត់ធន់ដរាបដល់ក្ស័យជីវិត បានទៅកើតក្នុងស្ថានតាវតិង្ស ឈ្មោះ "មណ្ឌូកទេវបុត្រ" នោះទៅ ។

## អានិសង្សកឋិន ៤ យ៉ាងគឺ:

១. **កុសលមូលតា** ជាឫសគល់នៃកុសលទាំងពួង.

២. **បធានតា** ជាប្រធាននៃបារមីទាំង ៣០.

៣. **បុញ្ញាភិវឌ្ឍនា** ជាទីចំរើនបុណ្យកុសល.

៤. **សម្បត្តិសមិទ្ធន្តា** ជាទីសម្រេចនូវសម្បត្តិទាំង ៣ ស្ថាន ។

## អានិសង្សកឋិន

ជាបុគ្គលាធិដ្ឋាន

---

## រឿងបុរសលិចសំពៅ

កាលពីព្រេងនាយមានបុរសម្នាក់ឈ្មោះតម្ពុលៈ នៅក្នុងសាវត្ថី បានធ្វើដំណើរទៅកាន់ឧត្តរាបថជនបទ ក្នុងគិម្ហរដូវក្ដៅខ្លាំងពេកចូលទៅជ្រកក្រោមម្លប់ឈើមួយបានជួបនឹងបុរសម្នាក់ដែលចូលទៅជ្រកមុន ។

បុរសចូលទៅជ្រកមុនបាននិយាយសុំស្លាម្លូថា ម្នាលសំឡាញ់អ្នកមានស្លាម្លូឬទេ ? បើមាន ខ្ញុំសុំទាន ១ ម៉ាត់ទទួលទានគ្រាន់មានទឹកមាត់ ព្រោះស្រេកទឹកខះកណាស់ ។ តម្ពុលៈបុរសឮសូមដូច្នោះហើយ មានចិត្តមេត្តាករុណា បានឱ្យម្លូស្លាមួយមាត់ទៅបុរសនោះបរិភោគ ។ កាលខាងក្រោយមកបុរសទាំងពីរនាក់ បានឡើងជិះសំពៅឆ្លងមហាសាគរទៅជួញជាមួយនឹងពួកឈ្មួញទាំងឡាយ

ទៅបាន ៧ ថ្ងៃមានខ្យល់ព្យុះជាខ្លាំងផ្ទាយសំពៅកណ្ដាលមហាសាគរ ពួកឈ្មួញទាំងឡាយត្រូវទឹករលកបោកលិច ស្លាប់អស់នៅសល់តែតម្កុលៈបុរស និងបុរសដែលបានសុំស្វាស៊ីក្នុងពេលដែលជ្រកក្រោមម្លប់ឈើ ឯបុរសដែលសុំម្ជូស្វាបានក្ដារមួយបន្ទះតោងហែលទៅដោយខ្សែក តម្កុលៈបុរសឥតបានក្ដារតោងទេ ខំហែលទៅដោយខ្សែកមានសេចក្ដីទុក្ខលំបាកយ៉ាងខ្លាំងស្ទើរតែនឹងស្លាប់ ជួនជាអាយុមិនអស់ ក៏អណ្ដែតទៅជួបនឹងបុរសដែលសុំស្វាម្ជូៗ នោះឃើញហើយចាប់លើកឡើងស្គាល់ច្បាស់ជាតម្កុលៈ បុរសដែលខ្លួនបានសុំម្ជូស្វាក៏ឱ្យបន្ទះក្ដារហែលឆ្លងទៅ ខ្លួនស៊ូហែលដៃទទេ ព្រោះនឹកឃើញគុណដែលឱ្យស្វាម្ជូ ១ ម៉ាត់ដល់ខ្លួនក្នុងពេលដែលខ្លួនស្រេកទឹកខ្លាំង ។

ឯតម្កុលៈបុរសកាលបើបានផែនក្ដារហើយ ក៏ខំហែលសំដៅទៅរកត្រើយចំណែកខាងបុរសអ្នកហែលដៃទទេ ក៏ចេះតែខំហែលយូរៗ ទៅអស់កម្លាំង ក៏បណ្ដែតខ្លួនទៅលើទឹក គិតថាអាយុអញអស់កណ្ដាលមហាសាគរនេះហើយ ប៉ុន្ដែស្លាប់ក៏ស្លាប់ចុះ ឱ្យតែតម្កុលៈបុរសអ្នកមានឧបការៈបានរស់ជីវិត កំពុងតែគិតយ៉ាងនេះ ក៏ក្ដៅក្រហាយដល់ទេវតារក្សាសមុទ្រ ទេវតារំពឹងមើលឃើញបុរសនោះមានគុណធម៌ល្អ ក៏ស្ទុះទៅស្រង់យកទៅដាក់នៅត្រើយនាយមុនតម្កុលៈបុរស លុះតម្កុលៈបុរសទៅដល់ស្រាប់តែឃើញបុរសនោះនៅលើច្រាំងទើបសួរថា សំឡាញ់ឯងបានអ្វីជិះមក បានជាឆាប់ដល់ម្ល៉េះ ។ បុរសនោះប្រាប់តាមត្រង់ថា ខ្ញុំឥតដឹងខ្លួនទេ អស់កម្លាំងពេកបណ្ដែតខ្លួនលើទឹកចាំតែពេលនឹងស្លាប់ ស្រាប់តែមកដល់ទីនេះតែម្ដង ។

កំពុងតែនិយាយដូច្នោះ ទេវតាក៏បង្ហាញខ្លួនឱ្យបុរសពីរនាក់ឃើញ ហើយនិយាយប្រាប់ថា ខ្ញុំយកអ្នកមក ព្រោះអ្នកមានកតញ្ញូកតវេទិតាធម៌ប្រាកដក្នុងខ្លួន បុគ្គលដែលមានសភាពដូចអ្នកនឹងបណ្ដោយឱ្យវិនាសមិនបានឡើយ តាំងពីព្រេងនាយមកទេវតាទាំងឡាយ មិនដែលមើលបំណាំបុគ្គលដែលប្រាកដស្មើដូចជាអ្នកនេះឡើយ ។ ទេវតាប្រាប់ដូច្នេះហើយ ក៏ឱ្យបុរសទាំងពីរបរិភោគអាហារទិព្វ ស្លៀកពាក់គ្រឿងអលង្ការទិព្វ ហើយនាំទៅដាក់ក្នុងនគរសាវត្ថី ក្នុងខណៈនោះឯង ។

## អានិសង្សមេត្តា ១១ យ៉ាង គឺ:

**១. សុខំ សុបតិ** បុគ្គលប្រកបដោយមេត្តា រមែងដេកលក់ជាសុខស្រួលល្អ ចំណែកជនដទៃរមែងដេកលក់អាក្រក់ គឺដេកបំរះនទ្បៀលស្រមុកលាន់ឮសម្លេងអាក្រក់ផ្សេងៗ បុគ្គលប្រកបដោយមេត្តា មិនដូច្នោះឡើយ ដេកលក់ជាសុខស្រួល ហាក់ដូចជាមនុស្សចូលមកកាន់សមាបត្តិ.

**២. សុខំ បដិពុជ្ឈតិ** អ្នកប្រកបដោយមេត្តា រមែងភ្ញាក់រឭកអំពីលក់ក៏ជាសុខស្រួលល្អ ចំណែកជនដទៃរមែងភ្ញាក់អំពីលក់អាក្រក់ គឺធ្វើសម្លេងថ្ងូរគ្រហឹមមិតពត់កាយ បំរះនទ្បៀលកាយផ្សេងៗ អ្នកប្រកបដោយមេត្តា មិនដូច្នោះឡើយ រមែងភ្ញាក់ឡើងជាសុខស្រួលល្អ ប្រៀបដូចជាផ្កាឈូករីក.

**៣. ន បាបកំ សុបិនំ បស្សតិ** អ្នកប្រកបដោយមេត្តា កាលនឹងដេកលក់ទៅ មិនបានយល់សប្តិឃើញអាក្រក់ឡើយ គឺយល់សប្តិឃើញល្អៗ ឃើញហាក់ដូចជាថ្វាយបង្គំចេតិយ ហាក់ដូចជាធ្វើបូជាព្រះរតនៈ ហាក់ដូចជា

ស្លាប់ធមិជាដើម ចំណែកជនដទៃរមែងយល់សប្តិឃើញហាក់ដូចជាចោរដេញ ហាក់ដូចជាមនុស្សពាលបៀតបៀន ឬ ហាក់ដូចជាធ្លាក់ទៅក្នុងជ្រោះជាដើម.

**៤. មនុស្សានំ បិយោ ហោតិ** អ្នកប្រកបដោយមេត្តា រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃមនុស្សទាំងឡាយប្រៀបដូចជាកែវមុក្តាហារសម្រាប់ពាក់ដើមទ្រូងនិងកម្រងផ្កាសម្រាប់ប្រដាប់ក្បាល.

**៥. អមនុស្សានំ បិយោ ហោតិ** អ្នកប្រកបដោយមេត្តា រមែងជាទីស្រឡាញ់គាប់ចិត្តនៃមនុស្សទាំងឡាយមានទេវតាជាដើម.

**៦. ទេវតា រក្ខន្តិ** ពួកទេវតារមែងរក្សាបុគ្គលដែលប្រកបដោយមេត្តា ប្រៀបដូចជាមាតាបិតាដែលរក្សាបុត្រ.

**៧. នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ** បុគ្គលដែលប្រកបដោយមេត្តា មិនបានឆេះរលាក ឬក្តៅក្រហាយដោយភ្លើង មិនបានស្លាប់វិនាសដោយពិសបំពុល មិនបានមុតដោយគ្រឿងសស្ត្រាវុធផ្សេងៗ.

**៨. តុវដំ ចិត្តំ សមាធិយតិ** ចិត្តអ្នកប្រកបដោយមេត្តា រមែងតាំងនៅខ្ជាប់ខ្ជួនល្អដោយឆាប់រហ័សមិនបានយឺតយូរឡើយ.

**៩. មុខវណ្ណោ វិប្បសីទតិ** អ្នកប្រកបដោយមេត្តា រមែងមានមុខស្រស់បស់ ប្រៀបដូចជាផ្លែត្នោតទុំដែលទើបនឹងជ្រុះចាកទង.

**១០. អសម្មូឡ្ហោ កាលំ ករោតិ** អ្នកប្រកបដោយមេត្តា រមែងមិនបានធ្វើមរណកាលដោយសេចក្តីវង្វេង គឺគ្មានសេចក្តីវង្វេងហើយស្លាប់ គឺថាស្លាប់ដូចគេដេកលក់ស្រួល.

**១១. ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ** អ្នកប្រកបដោយមេត្តា ទុកជាមិនបានត្រាស់ដឹងនូវគុណធម៌ខ្ពង់ខ្ពស់ជាងមេត្តាសមាបត្តិនោះទេ លុះច្យុតអំពីមនុស្សលោកនេះទៅ ក៏គង់តែបានទៅកើតក្នុងព្រហ្មលោកពុំខានឡើយ ។

## អានិសង្សមេត្តា

ជាបុគ្គលាធិដ្ឋាន

❖❖❖❖❖❖❖

## រឿងសក្កទេវរាជ

កាលកន្លងទៅហើយ មានមាណពម្នាក់ឈ្មោះមឃៈនៅក្នុងអចលគ្រាមក្នុងដែនមគធៈ បានធ្វើទីដីមួយកន្លែងឱ្យរាបស្មើគួរជាទីរីករាយ ។

មានមាណពដទៃទៀត មកបណ្តេញគាត់ឱ្យចេញពីទីនោះ ហើយនៅដោយខ្លួនឯង ។ មឃៈមាណពមិនខឹងសោះ. ហើយទៅធ្វើកន្លែងដទៃទៀត. គេបណ្តេញទៀត ទៅធ្វើកន្លែងដទៃជាច្រើនលើក ។ តមកខាងក្រោយ គាត់យកចបទៅជម្រះកន្លែង ១ ទំហំប៉ុនលានឱ្យរលីងស្អាត. ជនទាំងពួងតែងទៅកន្លែងនោះជានិច្ច. ក្នុងរដូវរងាមឃៈមាណពបំពក់ភ្លើងឱ្យ. ក្នុងរដូវក្តៅគាត់ដងទឹកឱ្យ។ តពីនោះមក មឃៈមាណពតែងចេញទៅពីព្រលឹមធ្វើផ្លូវឱ្យរាបស្មើ និងឆ្កាមែកឈើដែលគួរយកចេញ. មាណពឯទៀតៗ មកសួរ. គាត់ប្រាប់ថា ខ្ញុំធ្វើផ្លូវទៅស្ថានសួគ៌ ។ ទើបមាណពឯទៀតមកសូមធ្វើជាមួយផង បានគ្នាពីរនាក់

យូរៗ ទៅបានគ្នាម្តងម្នាក់-ម្តងពីរនាក់ ចំរើនបានគ្នា ៣៣ នាក់. ធ្វើផ្លូវបាន ប្រហែល ២ យោជន៍ ។

គ្រានោះ គាមភោជក (មេស្រុក) បានឃើញជនទាំងនោះធ្វើដូច្នោះក៏គិតថា "មនុស្សទាំងនេះប្រកបកិច្ចការដែលមិនគួរប្រកបសោះ. បើយកត្រីសាច់ជាដើមមកស៊ីផឹកសុរា ឬធ្វើកិច្ចដទៃក្រៅពីនេះវិញ សមជាអញបានកម្រៃបន្តិចបន្តួចមិនខាន. ទើបហៅមាណពទាំងនោះមកឃាត់មិនឱ្យធ្វើ ។ មាណពទាំងអស់នោះប្រកែកមិនព្រមឈប់ ។ គាមភោជកខឹងណាស់ ក៏ទៅក្រាបបង្គំទូលដល់មហាក្សត្រដោយពាក្យបង្កាច់ថា ខ្លួនបានឃើញពួកចោរនៅក្នុងព្រៃ ។ ព្រះរាជាទ្រង់បង្គាប់ឱ្យចាប់មាណពទាំងនោះមក ។ គាមភោជកក៏ចាប់នាំបង្គំថ្វាយតាមព្រះបង្គាប់ ។ ព្រះរាជាមិនបានពិចារណាសោះ ស្រាប់តែទ្រង់បង្គាប់ឱ្យយកដំរីមកបញ្ជាន់អ្នកទាំងនោះ ។ ឯមឃៈមាណពបានឱ្យឱវាទដល់សម្មាញ់របស់ខ្លួនទាំងអស់ថា ចូរអ្នកទាំងឡាយតាំងចិត្តមេត្តាឱ្យល្អ គ្មានអ្វីជាទីពឹងក្រៅពីមេត្តានេះទេ. អ្នកទាំងឡាយកុំខឹងនឹងព្រះរាជា នឹងគាមភោជកនឹងដំរីសម្រាប់បញ្ជាន់ ឬ នឹងខ្លួនឯងឡើយ. ចូរអ្នកមានចិត្តស្មើ ប្រកបដោយមេត្តាតែម្យ៉ាង. មាណពទាំងឡាយក៏ធ្វើតាម ។ ដោយអានុភាពនៃមេត្តាចិត្តរបស់ជនទាំងនោះដំរីក៏មិនហ៊ានជិតឡើយ ។ ព្រះរាជាទ្រង់ជ្រាបដូច្នោះហើយ ទើបមានព្រះឱង្ការថា "ដំរីឃើញមនុស្សច្រើនបានជាមិនហ៊ានជាន់" ទើបទ្រង់បង្គាប់ឱ្យយកកន្ទេលមកគ្របមនុស្សទាំងនោះ. ធ្វើដូច្នោះក៏ដំរីរឹតតែថយឆ្ងាយជាងមុនទៅទៀត. ទើបទ្រង់ត្រាស់ហៅមាណពទាំងនោះមកសួរហេតុតាំងពីដំបូងរៀងមក. បាន

ជ្រាបសព្វសេចក្តីហើយ ក៏មានព្រះទ័យសោមនស្ស ទ្រង់មានព្រះរាជឱង្ការថា "ម្នាលអ្នកទាំងឡាយ, អម្បាលសត្វតិរច្ឆាន ម្តេចក៏ដឹងគុណអ្នកទាំងឡាយ, ចុះអញជាមនុស្សត្រឡាំងក៏មិនដឹងសោះ, សូមអ្នកទាំងឡាយអត់ទោសផងចុះ" ហើយទ្រង់ឱ្យគាមភោជកព្រមទាំងប្រពន្ធកូនទៅជាខ្ញុំបម្រើមាណពទាំងនោះ, ទ្រង់ព្រះរាជទានដំរីនោះឱ្យជាយានជំនិះ និងស្រុកនោះឱ្យជារបស់មាណពទាំងឡាយ ។ មាណពទាំងឡាយមានសេចក្តីរីករាយដោយគំនិតថា "អានិសង្សបុណ្យយើងបានឃើញហើយ" ទើបប្រឹក្សាគ្នាថា "ឥឡូវនេះគួរតែយើងធ្វើបុណ្យឱ្យក្រៃលែងតទៅទៀត" លុះយល់ព្រមគ្នាហើយ ក៏ឱ្យហៅជាងឈើមក ឱ្យធ្វើសាលាសំណាក់ត្រង់ផ្លូវត្រឡែងកែងមួយអន្លើ, មិនឱ្យពួកស្រី១ ចូលធ្វើជាមួយផងឡើយ ។

ឯមឃៈមាណពមានប្រពន្ធ ៤ នាក់ គឺនាងសុធម្មា ១, សុនន្ទា ១, សុចិត្តា ១, សុជាតា ១ ។ នាងសុធម្មាត្រូវគំនិតគ្នានឹងជាងឈើ, នាងឱ្យសំណូកជាងឈើហើយនិយាយថា ត្រូវអ្នកឯងធ្វើឱ្យខ្ញុំបានជាធំក្នុងសាលានេះកុំខាន ។ ជាងឈើយល់ព្រមតាមហើយ ក៏ហាលឈើសម្រាប់ធ្វើហោជាងឱ្យស្ងួត ឈូសសំអាតស្រេចហើយឆ្លាក់អក្សរថា "នេះសាលាសុធម្មា" ។

លុះដល់វេលាដែលធ្វើសាលាហើយស្រេច ត្រូវលើកហោជាង ក៏និយាយពើធ្វើជាភ្លេចមិនបានធ្វើហោជាង, ហើយត្អូញត្អែរថា លុះតែបានហោជាងដែលគេធ្វើរួចស្រេចមុនមកទើបស្រួល ។

មាណពទាំងឡាយសួរថា ឥឡូវនេះ យើងត្រូវធ្វើដូចម្តេច ? ជាងឈើថា

យើងត្រូវរកហោជាងដែលគេធ្វើទុកលក់ស្រាប់ៗ ។ មាណពទាំងនោះបានឃើញហោជាងនៅផ្ទះនាងសុធម្មា. ក៏និយាយទិញឱ្យថ្លៃ ១ ពាន់កហាបណៈ ។ នាងសុធម្មាមិនព្រមលក់សោះ បែរជានិយាយថា បើអ្នកទាំងអស់ឱ្យខ្ញុំបានចំណែកបុណ្យក្នុងសាលានេះផង. ខ្ញុំមិនយកថ្លៃទេ ។ ជាងឈើជួយជម្រុលថាលោកម្ចាស់ហើយ. ឋានដទៃលើកលែងតែព្រហ្មលោកចេញ គ្មានឋានណាឥតមាតុគ្រាមទេ. សូមលោកយកហោជាងនេះចុះ. ខ្ញុំបាទនឹងធ្វើការឱ្យសម្រេចឆាប់ ។

មាណពទាំងនេះក៏ព្រមយកហោជាងនេះមកឱ្យជាងឈើធ្វើសាលាស្រេចហើយ ខណ្ឌជា ៣ ចំណែកគឺ ១ ចំណែកសម្រាប់អ្នកធំ ១ ចំណែកសម្រាប់មនុស្សទុគ៌ត ១ ចំណែកសម្រាប់មនុស្សមានជម្ងឺ ។ ជនទាំង ៣៣ នាក់នោះក្រាលផែនក្តារ ៣៣ បន្ទះ ១ បន្ទះម្នាក់ៗ ហើយសញ្ញាដល់ដំរីថា បើមនុស្សអាគន្តុកៈមកអង្គុយលើផែនក្តារអ្នកណា. ត្រូវឯងនាំទៅប្រគល់ដល់អ្នកម្ចាស់ក្តារនោះ. ការតក់ច្រចាច់និងម្ហូបចំណីគ្រប់យ៉ាងជាភារៈលើអ្នកម្ចាស់ក្តារនោះទាំងអស់ ។ ដំរីក៏ធ្វើតាម ។

ឯមឃៈមាណពបានដាំដើមរលួសផ្កុង ១ ដើមនៅក្បែរសាលា. ហើយក្រាលផែនថ្មប្របតល់រលួសផ្កុងនោះ ។ អ្នកផងដែលចូលទៅជិតសាលានោះតែបានមើលហោជាង តែងអានអក្សរនិយាយគ្នាថា "សាលាសុធម្មាៗ" ឈ្មោះមនុស្សទាំង ៣៣ នាក់នោះ មិនប្រាកដសោះ ។

ឯនាងសុនន្ទាគិតថា "មាណពទាំងនេះ កាលកសាងសាលាមិនឱ្យអញ

បានចំណែកបុណ្យផងឡើយ" ។

នាងសុធម្មាជាស្ត្រីឆ្លាត បានធ្វើហោជាង. ទើបបានចំណែកបុណ្យក្នុងសាលានេះ អញបើធ្វើអ្វីមួយនឹងគេទើបគួរ. តើអញធ្វើអ្វីអេះ ? ទើបនាងឱ្យជីកស្រះបោក្ខរណី ១ នៅប្រែសាលានោះ មានឈ្មោះប្រាកដថា "សុធម្មាបោក្ខរណី"

ឯនាងសុចិត្តាបានធ្វើសួនផ្កា ១. ជាមរណើយស្ថានជាទីគួរីករាយបុប្ផផលទាំងឡាយមានគ្រប់គ្រាន់ មានឈ្មោះប្រាកដថា "សុចិត្តលតាវ័ន" សម្រាប់មហាជនកំសាន្តចិត្ត ។ ឯនាងសុជាតាគិតថា "អញចាំបាច់ធ្វើអ្វីទៀត ព្រោះអញជាចិតារបស់ឪពុកធំមឃៈមាណព ហើយត្រូវជាប្រពន្ធរបស់មឃៈមាណពនេះស្រាប់. បើគាត់ធ្វើអ្វី ! ឈ្មោះថាអញធ្វើដែរ" ហើយក៏ខំតែស្អិតស្អាងអត្តភាពខ្លួនឯងប៉ុណ្ណោះ ។

ចំណែកខាងមឃៈមាណពបានបំពេញនូវវត្តបទ ៧ ប្រការ គឺការបំរើនូវមាតាបិតា ១ សេចក្តីប្រព្រឹត្តិកោតក្រែងដល់បុគ្គលជាធំក្នុងត្រកូល ១ វាចាទៀងទាត់ ១ វាចាស្រទន់ស្រទាប ១ វាចាមិនញុះញង់ ១ ការនាំបង់នូវសេចក្តីកំណាញ់ ១ សេចក្តីមិនក្រោធ ១ ឱ្យពេញគ្រប់គ្រាន់ ត្រូវត្រង់សេចក្តីសរសើរដែលលោកចងជាគាថាទុកមកថា:

**មាតាបេត្តិភរំ ជន្តុំ　　　កុលេ ជេដ្ឋាបចាយិនំ**
**សណ្ហំ សខិលសម្ភាសំ　　　បេសុណេយ្យប្បហាយិនំ**
**មច្ឆេរវិនយេយុត្តំ　　　សច្ចំ កោធាភិភុំ នរំ**

**តំ វេ ទេវា តាវតឹសា អាហុ សប្បុរិសោ ឥតិ ។**

(ប្រែថា) នរជនឯណា ជាអ្នកចិញ្ចឹមនូវមាតាបិតា ជាអ្នកមានសេចក្តីកោតក្រែងដល់អ្នកធំក្នុងត្រកូល ជាអ្នកពោលនូវពាក្យឬហត់ចត់ស្រទន់ស្រទាប ជាអ្នកលះលែងនូវពាក្យញុះញង់ ជាអ្នកនាំបង់នូវសេចក្តីកំណាញ់ ជាអ្នកនិយាយទៀងទាត់ ជាអ្នកគ្របសង្កត់នូវសេចក្តីក្រោធ. ពួកទេវតានៅស្ថានត្រៃត្រឹង្ស ហៅនរជននោះថា "សប្បុរស" ។

មឃមាណពនោះ លុះអស់ជីវិតទៅបានទៅកើតជាស្តេចទេវតាព្រះនាម "សក្ក" នៅពិភពតាវតឹង្ស ។

ឯមាណពជាសម្លាញ់ទាំងនោះ ក៏បានទៅកើតក្នុងពិភពតាវតឹង្សនោះដែរ។ ជាងឈើបានទៅកើតជាវិស្សកម្មទេវបុត្រ ។ ឯនាងសុធម្មាធ្វើមរណកាលទៅ បានទៅកើតក្នុងតាវតឹង្សនោះដែរ នាងមានទេវសភា (សាលាសម្រាប់ប្រជុំទេវតា) ១ ឈ្មោះសាលាសុធម្មា. ទំហំ ៥០០ យោជន៍ ឥតមានទីណាដទៃជាទីគួររីករាយជាងទេវសភានោះឡើយ ។

ឯនាងសុនន្ទា ធ្វើមរណកាលទៅ ក៏បានទៅកើតក្នុងឋានតាវតឹង្សនោះដែរ. នាងមានស្រះបោក្ខរណី ១ ឈ្មោះសុនន្ទាបោក្ខរណី. ទំហំ ៥០០ យោជន៍។

ឯនាងសុចិត្តា ធ្វើមរណកាលទៅ ក៏បានទៅកើតក្នុងឋានតាវតឹង្សនោះដែរ. នាងមានសួនច្បារ ១ ឈ្មោះសុចិត្តលតាវ័ន. ទំហំ ៥០០ យោជន៍ ។

ចំណែកខាងនាងសុជាតា ធ្វើមរណកាលទៅ បានទៅកើតជាមេកុកនៅក្នុងច្រកភ្នំមួយ ។

ព្រះឥន្ទឱ្យរក្សាសីល ៥ ហើយស្លាប់ទៅកើតជាកូនស្រីនាយស្មូនឆ្នាំង. ទ្រង់ណែនាំឱ្យរក្សាសីលទៀត។ ស្លាប់ទៅបានទៅកើតជាព្រះរាជធីតាព្រះបាទវេបចិត្រាសូរឈ្មោះនាងសុជាតានៅនាអសុរពិភព ទើបទ្រង់ទៅនាំមកតម្កល់ទុកជាមហេសី ក្នុងដំណែងជាធំជាងពួងស្រីអប្សរ ចំនួន ២ កោដិកន្លះ ឯឋានតាវតិំសុរសួគ៌នាយ ។

## អានិសង្សសមាធិភាវនា មាន ៥ យ៉ាង

**១. ទិដ្ឋធម្មសុខវិហារានិសំសា** អប្បនាសមាធិភាវនាមានកិរិយានៅជាសុខ ក្នុងបច្ចុប្បន្នជាអានិសង្ស ។

អធិប្បាយៈ ព្រះខីណាស្រពទាំងឡាយ កាលបើមានប្រាថ្នាដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ហើយចំរើននូវសមាធិ ចូលទៅកាន់ឈានមានចិត្តតម្កល់នៅឯកឯងក្នុងអារម្មណ៍តែ ១ លោកក៏បានជៀសចេញចាកអារម្មណ៍ផ្សេងៗ សម្ងំនៅជាសុខអស់ថ្ងៃ ១ បាន ។

**២. វិបស្សនានិសំសា** ទាំងអប្បនាសមាធិភាវនា ទាំងឧបចារសមាធិភាវនា សុទ្ធតែមានវិបស្សនាជាអានិសង្ស ជាភាវនាដូចគ្នា ។

អធិប្បាយៈ សេខបុគ្គលនិងបុថុជ្ជន កាលបើចេញចាកអំពីសមាបត្តិមកកំពុងមានចិត្តតម្កល់នៅមាំហើយពិចារណានូវវិបស្សនា ក៏និងបានដឹងច្បាស់នូវធម៌ដែលពិត ព្រោះសមាធិភាវនា ជាបទដ្ឋាននៃវិបស្សនា ។

**៣. អភិញ្ញានិសំសា** អប្បនាសមាធិភាវនា មានអភិញ្ញាជា

អានិសង្ស ។

អធិប្បាយ: ព្រះយោគីទាំងឡាយ ដែលញ៉ាំងសមាបត្តិទាំង ៨ ឱ្យកើតឡើងបាន វេលាដែលចេញចាកសមាបត្តិមកវិញ បើមានប្រាជ្ញាដើម្បីញ៉ាំងអភិញ្ញាឱ្យកើតឡើងបាន ។

**៤. ភវវិសេសានិសំសា** សមាធិភាវនាទាំង ២ មានសម្បត្តិយ៉ាងវិសេសនៅក្នុងភពជាអានិសង្ស ។

អធិប្បាយ: អប្បនាសមាធិភាវនា នាំមកនូវសម្បត្តិយ៉ាងវិសេសក្នុងព្រហ្មលោក គឺថាព្រះយោគីដែលចំរើនបានដល់ថ្នាក់បឋមជ្ឈានជាដើមហើយ ប៉ុន្តែមិនបានសាបសូន្យចាកឈានទាំងនោះទេ ទុកណាជាប្រាជ្ញាក្តី មិនប្រាជ្ញាក្តី ដល់ពេលដែលធ្វើកាលកិរិយាទៅ ក៏គង់នឹងទៅកើតក្នុងព្រហ្មលោកជាប្រាកដ ឯឧបចារសមាធិភាវនានាំមកនូវសម្បត្តិយ៉ាងវិសេសក្នុងកាមាវចរសុគតិភពទាំង ៦ ជាន់ ។

**៥. និរោធានិសំសា** អប្បនាសមាធិភាវនា មាននិរោធជាអានិសង្ស ។

អធិប្បាយ: ព្រះអរិយបុគ្គលទាំងឡាយ កាលបើញ៉ាំងសមាបត្តិទាំង ៨ ឱ្យកើតឡើង ហើយចូលកាន់និរោធសមាបត្តិ នឹងបានដល់នូវនិរោធនិព្វាន មានសភាពជាបុគ្គលមិនមានចិត្ត គង់នៅនាសុខក្នុងបច្ចុប្បន្នថ្ងៃ ៧ បាន ។

## ភាវនាបានសម្រេចផល ៣ យ៉ាង គឺៈ

១- អរហត្តមគ្គ. ២- អរហត្តផល. ៣- ព្រះនិព្វាន ។

## អានិសង្សចំរើនភាវនា

ជាបុគ្គលាធិដ្ឋាន

◆◆◆◆◆

# រឿងព្រះយសកុលបុត្រ

ព្រះយសកុលបុត្រនេះ ជាបុត្រនាងសុជាតា ធិតាសេនិយសេដ្ឋីនៅសេនានិគម ។ ពីដើមនាងសុជាតាជាមាតាបានបន់ទេវតានៅដើមជ្រៃ ដើម្បីឱ្យបានកូនប្រុសច្បង. លុះបានសម្រេចដូចបំណង ក៏ធ្វើពលិការ ១ ឆ្នាំម្តង ។ ដរាបដល់ព្រះយសនេះធំឡើង ។ វេលាវិសាខបុណ្ណមីថ្ងៃដែលព្រះសម្ពុទ្ធបានត្រាស់ នាងសុជាតាយកមធុបាយាសទៅបូជាទេវតា ក៏ជូនជាបានជួបនឹងព្រះអង្គ ។ លុះទ្រង់បានត្រាស់ហើយ ទ្រង់ស្តេចទៅចាំជួបនឹងព្រះយសនេះនៅព្រៃឥសិបតនៈ ។

ព្រះយសនោះ អផ្សុកមិនចង់នៅផ្ទះ ក៏លបចេញមកទាំងយប់. ព្រឹកឡើងបានជួបនឹងព្រះអង្គ បានស្តាប់ធម៌ទេសនា សម្រេចអនាគាមិផលបានបួសជាឯហិភិក្ខុ ទើបបិតាតាមមកទាន់ ។ បិតាស្តាប់ធម៌ហើយបានលុះស្រោតា ទើបនិមន្តព្រះអង្គទៅផ្ទះ ។ នាងសុជាតានិងភរិយាយសកុលបុត្រព្រមទាំងសំឡាញ់ ៥២ នាក់ស្តាប់ធម៌ហើយ បានលុះស្រោតា. បិតាបានលុះអនាគាមិ.

នាងសុជាតាបានដល់សរណគមន៍ បានឋានន្តរជាឯតទគ្គខាងឯដល់សរណគមន៍មុនគេ ។ សំឡាញ់ទាំង ៥៤ នាក់ចូលបួសតាមព្រះយសកុលបុត្តនេះទាំងអស់ ។

ភិក្ខុទាំងឡាយក្រាបបង្គំសួរ បពិត្រព្រះអង្គដ៏ចំរើន ជនទាំង ៥៥ នាក់មានយសកុលបុត្រជាដើម បានធ្វើនូវបុញ្ញកម្មដូចម្ដេច ? ព្រះសាស្ដាជាម្ចាស់ទ្រង់ត្រាស់ថា ជនទាំងនុ៎ះ កាលដែលប្រាថ្នាព្រះអរហត្តបានធ្វើបុណ្យជាច្រើនក្នុងសំណាក់ព្រះពុទ្ធមួយព្រះអង្គ.

លុះចំណេរមកខាងក្រោយ កាលដែលព្រះពុទ្ធមិនទាន់ឧប្បត្តិឡើងក្នុងលោក ជនទាំងនោះជាសំឡាញ់នឹងគ្នាតែងរួបរួមកម្លាំងគ្នាធ្វើបុណ្យនិងទំនុកបម្រុងសរីរៈ អនាថា:

ថ្ងៃមួយ ជនទាំងនោះបានឃើញមនុស្សស្រីស្លាប់ទាំងគភ៌ ក៏នាំយកទៅឯព្រៃស្មសានដោយគិតថា នឹងធ្វើឈាបនកិច្ច. លុះទៅដល់ក៏ទុកតែជន ៥ នាក់ឱ្យនៅធ្វើឈាបនកិច្ច. ជនសល់ពីនោះចូលទៅស្រុកវិញ ។

ឯយសទារក កាលដែលកំពុងចាក់ប្រមៀលធ្វើឈាបនកិច្ចសរីរៈនោះ ក៏បាននូវអសុភសញ្ញា ហើយក៏បង្ហាញដល់ជន ៤ នាក់ទៀតថា គ្នាយើងអើយអ្នកទាំងឡាយមើលចុះហ្ន៎ ! សរីរៈនេះមានស្បែករបេះរបោចដូចជារូបគោពពាលមិនស្អាតមានក្លិនស្អុយគួរឱ្យខ្ពើមរអើមក្រៃពេក ។ ជនទាំងឡាយនោះក៏បានអសុភសញ្ញាដែរ. ហើយនាំគ្នាចូលទៅស្រុកវិញ ដំណាលប្រាប់សំឡាញ់ទាំងអស់សព្វគ្រប់ប្រការ ។ មិនតែប៉ុណ្ណោះ យសទារកបានដំណាលប្រាប់មាតាបិតានិងភរិយាទៀត. ជនទាំងនោះក៏បានចំរើនអសុភសញ្ញាតទៅ ។

នេះឯងជាបុព្វកម្មនៃជនទាំងនោះ. ព្រោះហេតុនោះបានជាយសទារក មានសេចក្ដីសំគាល់ក្នុងផ្ទះជាទីប្រាថ្នាថា ដូចជាព្រៃស្មសាន ។ ជនទាំងនោះបាន ត្រាស់ដឹងនូវធម៌ ដ៏វិសេសដោយឧបនិស្ស័យសម្បត្តិនោះឯង ។

ជនទាំង ៥៥ នាក់នោះ បានសម្រេចដូចសេចក្ដីប្រាថ្នា ដែលខ្លួនតម្កល់ ទុកហើយយ៉ាងនេះ. តថាគតមិនមែនឱ្យបាននូវព្រោះយល់មុខទេ ។

# ធុតង្គកថា

ពាក្យថា ធុតង្គនេះ បើនិយាយឱ្យងាយស្ដាប់ បានសេចក្ដីថា អង្គរបស់ បុគ្គលអ្នកកំចាត់បង់នូវកិលេស ឬថា: ធម្មជាតមានញាណសម្រាប់កំចាត់បង់ នូវកិលេសជាអង្គ ។

ន័យមួយទៀតថា អង្គនៃសេចក្ដីប្រតិបត្តិសម្រាប់កំចាត់បង់នូវធម៌ជា សត្រូវ រួមមក សំដៅយកសមាទានចេតនា គឺចេតនាសម្រាប់សមាទាននូវអង្គ នោះៗ ។

# ធុតង្គមាន ១៣ គឺ:

១. **បំសុកូលិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយាទ្រទ្រង់នូវចីវរ ដែលដល់នូវភាពគួរខ្ពើម ដូចជាអាចម៍ដីជាប្រក្រតី ។

២. **តេចីវរិកង្គ:** អង្គរបស់ភិក្ខុ អ្នកមានតែចីវរ ៣ (សង្ឃាដី ចីពរ-ស្បង់) ជាប្រក្រតី ។

៣. **បិណ្ឌបាតិកង្គ:** អង្គរបស់ភិក្ខុអ្នកមានកិរិយាត្រាច់ទៅ ដើម្បី

បិណ្ឌបាតជាវត្ត ។

៤. **សបទានចារិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាត្រាច់ទៅដើម្បីបិណ្ឌបាតរៀងតាមលំដាប់នៃផ្ទះជាប្រក្រតី ។

៥. **ឯកាសនិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាបរិភោគនូវភោជន តែក្នុងអាសនៈ ១ ជាប្រក្រតី ។

៦. **បត្តបិណ្ឌិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាបរិភោគនូវភោជនតែក្នុងបាត្រ[១] ១ ជាប្រក្រតី ។

៧. **ខលុបច្ឆាភត្តិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាមិនបរិភោគនូវភត្ត ដែលខ្លួនហាមភោជនរួចហើយ ទើបបានមកក្នុងកាលជាខាងក្រោយជាប្រក្រតី ដោយអំណាចនៃធុតង្គសមាទាន ។

៨. **អារញ្ញិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យក្នុងព្រៃជាប្រក្រតី ។

៩. **រុក្ខមូលិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យទៀបគល់នៃឈើជាប្រក្រតី ។

១០. **អព្ភោកាសិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យក្នុងទីអាវាសស្រឡះជាប្រក្រតី ។

១១. **សោសានិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យ

---

១-បាត្រក្នុងទីនេះមិនសំដៅយកតែបាត្រត្រង់១ តែម្យ៉ាងទេ ទុកណាជាភាជនៈដទៃ ក៏ហៅថាបាត្រដែរ ។

ក្នុងព្រៃស្មសាន[១] ជាប្រក្រតី ។

**១២. យថាសន្ថតិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅតែក្នុងទីសេនាសនៈ ដែលសំដែងឱ្យជាដំបូងដដែលមិនរើរុះជាប្រក្រតី ។

**១៣. នេសជ្ជិកង្គៈ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាឃាត់នូវឥរិយាបថដេកហើយនៅដោយឥរិយាបថអង្គុយជាប្រក្រតី ។

អំពី **"ធុតង្គ"** ទាំង ១៣ មិនបានអធិប្បាយទេ ព្រោះក្នុងសៀវភៅនេះ និយាយតែពីអានិសង្សប៉ុណ្ណោះដើម្បីនឹងសំដែងឱ្យឃើញថា តើក្នុងធុតង្គមួយៗ មានអានិសង្សយ៉ាងណាខ្លះ ? ដូចមានខាងមខនេះ :

## អានិសង្សក្នុងបំសុកូលិកង្គ មាន ១២ យ៉ាង

**១. និស្សយានុរូបប្បដិបត្តិសព្ភាវោ** សភាពជាអ្នកមានសេចក្តីប្រតិបត្តិដ៏សមគួរដល់និស្ស័យ ដែលឧបសម្បទាចារ្យប្រៀនប្រដៅមកអំពីខាងដើមថា "បព្វជ្ជាត្រូវអាស្រ័យនូវបំសុកូលចីវរ" ដូច្នេះជាដើម ។

**២. បឋមេ អរិយវំសេ បតិដ្ឋានំ** កិរិយាតាំងនៅក្នុងអរិយវង្សទី ១[២] ។

---

១-កន្លែងសម្រាប់ចោលឬដុតខ្មោច ( ប៉ាឆា ) ។

២- អរិយវង្សមាន ៤ យ៉ាងគឺ: សន្តោសក្នុងចីវរ ១, សន្តោសក្នុងបិណ្ឌបាត ១, សន្តោសក្នុងសេនាសនៈ ១, សន្តោសក្នុងភេសជ្ជៈ ១ ។

៣. **អាវក្ខនុក្ខាភាវោ** មិនទុក្ខព្រោះកិរិយារក្សានូវចីវរ ។

៤. **អបរាយត្តវុត្តិតា** ភាពជាអ្នកមិនប្រព្រឹត្តជាប់ដោយបុគ្គលទៃ។

៥. **ចោរភយេន អភយតា** ភាពជាអ្នកមិនមានភ័យព្រោះខ្លាចចោរ ។

៦. **បរិភោគតណ្ហាយ អភាវោ** មិនមាននៃតណ្ហាក្នុងគ្រឿងប្រើប្រាស់ ។

៧. **សមណសារុប្បបរិក្ខារតា** ភាពជាអ្នកមិនមានគ្រឿងបរិក្ខារដ៏សមគួរដល់សមណៈភេទ ។

៨. **ភគវតា សំវណ្ណិតប្បច្ចយតា** ភាពជាអ្នកមានបច្ច័យដែលព្រះមានព្រះភាគទ្រង់សរសើរ ។ ( បច្ច័យបែបនេះព្រះសម្ពុទ្ធទ្រង់សរសើរថា "តិចផង ងាយផង ឥតទោសផង" ) ។

៩. **បាសាទិកតា** ភាពជាអ្នកនាំមកនូវសេចក្ដីជ្រះថ្លាដល់បុគ្គលដទៃ។

១០. **អប្បិច្ឆតាទីនំ ផលនិប្ផត្តិ** កិរិយាសម្រេចនៃផលរបស់អប្បិច្ឆតាគុណជាដើម ។

១១. **សម្មាបដិបត្តិយា អនុព្រូហនំ** កិរិយាបង្កើតនូវសម្មាបដិបត្តិ។

១២. **បច្ឆិមាយ ជនតាយ ទិដ្ឋានុគតិអាបាទនំ** កិរិយាញ៉ាំងប្រជុំជនជំនាន់ក្រោយឱ្យយកតម្រាប់តាម ។

ទាំង ១២ យ៉ាងនេះ ជាអានិសង្សក្នុងបំសុកូលិកង្គ ដែលភិក្ខុបានរក្សាដោយល្អមិនបានឱ្យបែកធ្លាយ ។

# អានិសង្សក្នុងតេចីវរិកង្គ មាន ១១ យ៉ាង

១. **សន្តុដ្ឋោ** បានឈ្មោះថាជាអ្នកមានសេចក្តីសន្តោស ដោយចីវរល្មមរក្សានូវកាយបាន ។

២. **សមាទាយេវគមនំ** កិរិយាកាន់យកតែចីវរ ៣ ប៉ុណ្ណោះដើរទៅ ហាក់ដូចជាសត្វបក្សី ។

៣. **អប្បសមារម្ភតា** ភាពជាអ្នកមានរវល់តិច ព្រោះមិនមានកិច្ចដែលត្រូវហាលសំដីល ឬបត់ទុកនូវអតិរេកចីវរជាដើម ។

៤. **វត្ថសន្និធិបរិវជ្ជនំ** កិរិយាវៀរបង់នូវកិរិយាសន្សំទុកនូវសំពត់ ។

៥. **សល្លហុកវុត្តិតា** ភាពជាអ្នកប្រព្រឹត្តស្រាលរហ័ស ។

៦. **អតិរេកចីវរលោលុប្បប្បហានំ** កិរិយាលះបង់នូវសេចក្តីលោភហួសកំរិត ក្នុងអតិរេកចីវរ ។

៧. **កប្បិយមត្តការិតា** ភាពជាអ្នកធ្វើនូវប្រមាណក្នុងចីវរដែលគួរ ។

៨. **សល្លេខវុត្តិតា** ភាពជាអ្នកព្រឹត្តក្បៀលឬបង្រួចនូវកិលេសឱ្យស្តើងចុះ ។

៩. **អប្បិច្ឆតាទីនំ ផលនិប្ផត្តិ** កិរិយាសម្រេចនូវផលនៃអប្បិច្ឆតាគុណជាដើម ។

១០. **សម្មាបដិបត្តិយា នុព្រូហនំ** កិរិយាបង្កើននូវសម្មាបដិបត្តិ ។

១១. **បច្ឆិមាយ ជនតាយ ទិដ្ឋានុគតិអាបាទនំ** កិរិយាញុំាង

ប្រជុំជនជំនាន់ក្រោយឱ្យយកតម្រាប់តាម ។

ទាំង ១១ នេះ ជាអានិសង្សក្នុងតេចីវរិកង្គ ដែលភិក្ខុបានរក្សាដោយល្អ មិនបានឱ្យបែកធ្លាយ ។

## អានិសង្សក្នុងបិណ្ឌបាតិកង្គ មាន១៥យ៉ាង

១. **និស្សយានុរូបប្បដិបត្តិសព្ភាវោ** សភាពជាអ្នកមានសេចក្តីប្រតិបត្តិដ៏សមគួរដល់និស្ស័យ ។

២. **ទុតិយេ អរិយវំសេ បតិដ្ឋានំ** កិរិយាតម្កល់នៅក្នុងអរិយវង្សទីពីរ ។

៣. **អបរាយត្តវុត្តិតា** ភាពជាអ្នកមិនមានកិរិយាប្រព្រឹត្តជាប់ដោយបុគ្គលដទៃ ។

៤. **ភគវតា សំវណ្ណិតប្បច្ចយតា** ភាពជាអ្នកមានបច្ច័យដែលព្រះមានព្រះភាគទ្រង់សរសើរ ។

៥. **កោសជ្ជនិម្មទនតា** ភាពនៃកិរិយាញាំញីនូវសេចក្តីខ្ជិលច្រអូស ។

៦. **បរិសុទ្ធាជីវិតា** ភាពជាអ្នកមានសេចក្តីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតដ៏ស្អាត ។

៧. **សេខិយប្បដិបត្តិបូរណំ** កិរិយាបំពេញនូវសេចក្តីប្រតិបត្តិក្នុងសេខិយវត្ត ។

**៨. អបរះឆាសិតា** ភាពជាអ្នកមិនចិញ្ចឹមនូវបុគ្គលដទៃ ព្រោះដឹងនូវប្រមាណក្នុងកិរិយាទទួល ។

**៩. បរានុគ្គហកិរិយា** កិរិយាធ្វើនូវសេចក្ដីអនុគ្រោះដល់បុគ្គលដទៃ ព្រោះទទួលនូវបិណ្ឌបាតបន្តិចៗ ក្នុងត្រកូលនោះៗ ។

**១០. មានប្បហានំ** សេចក្ដីព្យាយាមលះនូវមានះ ។

**១១. រសតណ្ហាយ និវារណំ** កិរិយាឃាត់នូវសេចក្ដីចំណង់ក្នុងរស់របស់ភោជនដទៃទៀត ។

**១២. គណភោជន បរម្បរភោជនចារិត្តសិក្ខាបទេហិ អនាបត្តិតា** ភាពជាអ្នកមិនមានអាបត្តិ ដោយគណភោជនសិក្ខាបទ បរម្បរ-ភោជនសិក្ខាបទ និងចារិត្តសិក្ខាបទ ព្រោះមិនមានទទួលនិមន្ត ។

**១៣. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** ភាពជាអ្នកមានកិរិយាប្រព្រឹត្តដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

**១៤. សម្មាបដិបត្តិព្រូហនំ** កិរិយាបង្កើតនូវសម្មាបដិបត្តិ ។

**១៥. បច្ឆិមាជនតានុគ្គហនំ** កិរិយាអនុគ្រោះដល់ប្រជុំជនជំនាន់ក្រោយ ។

ទាំង ១៥ យ៉ាងនេះ ជាអានិសង្សក្នុងបិណ្ឌបាតិកង្គ ដែលភិក្ខុបានរក្សាហើយដោយល្អ មិនឱ្យបែកធ្លាយ ។

*****

# អានិសង្សក្នុងសបទានចារិកង្គ មាន ៨ យ៉ាង

**១. កុលេសុ និច្ចនវកតា** ភាពជាបុគ្គលថ្មោងអស់កាលជានិច្ច ក្នុងត្រកូលទាំងឡាយ ។

**២. ចន្ទូបមតា** ភាពជាបុគ្គលល្អប្រៀបដូចជាព្រះចន្ទ្រ ព្រោះមិនមានជាប់ជំពាក់នៅក្នុងត្រកូលទាំងពួង ។

**៣. កុលមច្ឆេរប្បហានំ** កិរិយាលះបង់នូវសេចក្តីកំណាញ់ក្នុងត្រកូល ។

**៤. សមានុកម្បិតា** ភាពជាអ្នកមានសេចក្តីអនុគ្រោះស្មើគ្រប់ត្រកូលទាំងអស់ ។

**៥. កុលុបកាទីនវាភាវោ** មិនមានទោសក្នុងកិរិយាចូលទៅកាន់ត្រកូល ។

**៦. អវ្ហានានភិនន្ទនា** កិរិយាមិនទទួលត្រេកអរនូវពាក្យដែលគេហៅរកដោយការនិមន្ត ។

**៧. អភិហារេន អនត្ថិកតា** ភាពជាអ្នកមិនមានសេចក្តីត្រូវការដោយភិក្ខាដែលគេនាំមកឱ្យ ។

**៨. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** ភាពជាអ្នកមានកិរិយាប្រព្រឹត្តដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៨ យ៉ាងនេះ ជាអានិសង្សក្នុងសបទានចារិកង្គ ដែលភិក្ខុបានរក្សាទុកហើយដោយល្អ មិនឱ្យបែកធ្លាយទៅវិញ ។

## អានិសង្សក្នុងឯកាសនិកង្គ មាន ៨ យ៉ាង

**១. អប្បាពាធតា** ភាពជាអ្នកមានអាពាធតិច ។

**២. អប្បាតង្កតា** ភាពជាអ្នករស់នៅមិនលំបាក គឺមិនមានសេចក្ដីទុក្ខក្នុងសរីរៈ ។

**៣. លហុដ្ឋានំ** កិរិយាក្រោកឡើងរហ័ស ។

**៤. ពលំ** មានកម្លាំងក្នុងសរីរៈ ។

**៥. ផាសុវិហារោ** កិរិយានៅជាសុខសប្បាយ ។

**៦. អនតិរិត្តប្បច្ចយា អនាបត្តិ** មិនត្រូវអាបត្តិ ព្រោះបច្ច័យនៃកិរិយាបរិភោគនូវអនតិរិត្តភោជន ។

**៧. រសតណ្ហាយវិនោទនំ** កិរិយាបន្ទន់នូវសេចក្ដីចំណង់ក្នុងរស ។

**៨. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** ភាពជាអ្នកមានកិរិយាប្រព្រឹត្តដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៨ យ៉ាងនេះ ជាអានិសង្សក្នុងឯកាសនិកង្គ ដែលភិក្ខុបានរក្សាហើយដោយល្អ មិនឱ្យបែកធ្លាយ ។

## អានិសង្សក្នុងបត្តបិណ្ឌិកង្គ មាន ៦ យ៉ាង

**១. នានារសតណ្ហាវិនោទនំ** កិរិយាបង្អង់នូវសេចក្ដីចំណង់ក្នុងភោជនដែលមានរសផ្សេងៗ ។

**២. អត្រិច្ឆតាយ បហានំ** កិរិយាលះបង់នូវភាពជាអ្នកមាន

សេចក្តីប្រាថ្នាកន្លងក្នុងភោជននោះៗ ។

**៣. អាហារេ បយោជនមត្តញ្ញុតា** ភាពជាអ្នកឃើញនូវប្រមាណនៃប្រយោជន៍ក្នុងអាហារ ។

**៤. ថាលកាទិបរិហារេន ខណ្ឌាភាវោ** មិនមានសេចក្តីលំបាកព្រោះកិរិយារក្សាទុកភាជនៈជាដើម ។

**៥. អវិក្ខិត្តភោជិតា** ភាពជាអ្នកមិនបរិភោគមានចិត្តសាវាក្នុងភោជនផ្សេង ៗ ។

**៦. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** ភាពជាអ្នកមានកិរិយាប្រព្រឹត្តដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៦ យ៉ាងនេះ ជាអានិសង្សក្នុងបត្តបិណ្ឌិកង្គ ដែលភិក្ខុបានរក្សាហើយដោយល្អមិនឱ្យបែកធ្លាយ ។

## អានិសង្សក្នុងខលុបច្ឆាភត្តិកង្គ មាន ៥ យ៉ាង

**១. អនតិរិត្តភោជនាបត្តិយា ទូរីភាវោ** ភាពជាអ្នកឆ្ងាយចាកអាបត្តិ ដែលត្រូវព្រោះកិរិយាបរិភោគនូវអនតិរិត្តភោជន ។

**២. ឱទរិកត្តាភាវោ** មិនមាននៃភាពជាអ្នកមានអាហារចើសពោះ ( ចាក់ក្រាស ) ។

**៣. និរាមិសសន្និធិតា** ភាពជាអ្នកមិនសន្សំទុកនូវអាមិស ។

**៤. បុនបរិយេសនាយ អនុស្សុក្កោ** មិនមាននៃកិរិយាស្វែងរកទៀត ។

**៥. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** ភាពជាអ្នកមានកិរិយាប្រព្រឹត្តដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៥ នេះ ជាអានិសង្សក្នុងខលុបច្ឆាភត្តិកង្គ ដែលភិក្ខុបានរក្សាហើយដោយល្អមិនឱ្យធ្លុះធ្លាយ ។

## អានិសង្សក្នុងអារញ្ញិកង្គ មាន ៦ យ៉ាង

**១. ភព្វោ អលទ្ធំ វា សមាធឹ បដិលទ្ធុំ** ជាបុគ្គលគួរ ដើម្បីបាននូវសមាធិ ដែលមិនទាន់បាននៅឡើយ ។

**២. លទ្ធំ វា រក្ខិតុំ** ជាបុគ្គលគួរដើម្បីរក្សាទុកនូវសមាធិ ដែលបានរួចហើយ ។

**៣. សត្ថាបិស្ស អត្តមនោ** ព្រះសាស្តាសោតក៏នឹងពេញព្រះហឫទ័យ ចំពោះភិក្ខុនោះ ។

**៤. សប្បាយ រូបាទយោ ចិត្តំ នវិក្ខិបន្តិ** រូបារម្មណ៍ដែលមិនជាទីសប្បាយជាដើម និងមិនកំចោករោគនូវចិត្តរបស់ភិក្ខុនោះបាន ។

**៥. វិគតសន្តាសោ** ជាអ្នកមានសេចក្តីតក់ស្លុតប្រាសចេញ ។

**៦. ជីវិតនិកន្តី បជហាតិ** រមែងលះបង់ ។

## អានិសង្សក្នុងរុក្ខមូលិកង្គ មាន ៦ យ៉ាង

**១. និស្សយានុរូបប្បដិបត្តិសព្ភាវតា** សភាពជាអ្នកមានសេចក្ដីប្រតិបត្តិដ៏សមគួរដល់និស្ស័យ ដែលឧបសម្បទាចារ្យប្រៀនប្រដៅក្នុង ឧបសម្បទមណ្ឌលថា: "បព្វជ្ជាត្រូវអាស្រ័យនូវរុក្ខមូលសេនាសនៈ" ដូច្នេះជាដើម ។

**២. តគឃតាសំវណ្ណិតប្បច្ចយតា** ភាពជាអ្នកមានបច្ច័យ ដែលព្រះមានព្រះភាគទ្រង់សរសើរថា: "តិចផង រកបានដោយងាយផង ឥតទោសផង" ។

**៣. អនិច្ចសញ្ញាសមុដ្ឋាបនតា** ភាពនៃការញ៉ាំងអនិច្ចសញ្ញាឱ្យកើតឡើងបាន ដោយបានឃើញនូវការរបស់ដើមឈើនិងស្លឹកឈើរឿយៗ ។

**៤. សេនាសនមច្ឆេរកម្មារាមតានំ អភាវតា** មិនមាននៃសេចក្ដីកំណាញ់ ក្នុងសេនាសនៈ និងភាពជាអ្នកត្រេកអរក្នុងការងារ ។

**៥. ទេវតាហិ សហវាសិតា** ភាពជាអ្នកបាននៅរួមជាមួយនឹងទេវតាទាំងឡាយ ។

**៦. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** ភាពជាអ្នកមានកិរិយាប្រព្រឹត្តដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៦ នេះ ជាអានិសង្សក្នុងរុក្ខមូលិកង្គ ដែលភិក្ខុបានរក្សាហើយដោយល្អ មិនឱ្យបែកធ្លាយ ។

## អានិសង្សក្នុងអព្ភោកាសិកង្គ មាន ៥ យ៉ាង

**១. អាវាសបលិពោធុបច្ឆេទោ** កិរិយាផ្ដាច់បង់នូវសេចក្ដីកង្វល់ក្នុងអាវាស ។

**២. ថីនមិទ្ធប្បនូទនំ** កិរិយាបង្អន់នូវសេចក្ដីច្រអូសកាយនិងច្រអូសចិត្ត ។

**៣. និស្សង្គតា** ភាពជាអ្នកមិនទទាក់ទទាមដោយការហួងហែងនូវអាវាស ។

**៤. ចាតុទ្ទិសតា** ភាពជាអ្នកត្រាច់ទៅកាន់ទិសទាំង ៤ បានឥតមានទើសទាល់ ដោយមិនព្រួយក្រែងគ្មានទីលំនៅ ។

**៥. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** ភាពជាអ្នកមានកិរិយាប្រព្រឹត្តដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៥ នេះ ជាអានិសង្សក្នុងអព្ភោកាសិកង្គ ដែលភិក្ខុបានរក្សាហើយដោយល្អមិនឱ្យបែកធ្លាយ ។

## អានិសង្សក្នុងសោសានិកង្គ មាន ១០ យ៉ាង

**១. មរណសតិប្បដិលាភតា** កិរិយាបាននូវមរណស្សតិ ដោយបានឃើញនូវសាកសពអស់កាលជានិច្ច ។

**២. អប្បមាទវិហារតា** ភាពជាអ្នកទៅដោយសេចក្ដីមិនប្រមាទដោយកិរិយាបាននូវមរណស្សតិនោះ ។

**៣. អសុភនិមិត្តាធិគមោ** កិរិយាបាននូវអសុភនិមិត្តដោយបាន ឃើញនូវសាកសពដែលគេចោលទៅក្នុងទីស្មសាននោះ ។

**៤. កាមរាគវិនោទនំ** កិរិយាបង្អន់នូវកាមរាគ ដោយកិរិយាបាន នូវអភសុភនិមិត្តនោះ ។

**៥. អភិណ្ហំ កាយសភាវទស្សនំ** កិរិយាឃើញនូវសភាពរបស់ កាយដែលមិនស្អាតជាដើមរឿយៗ ។

**៦. សំវេគពហុលតា** ភាពជាអ្នកច្រើនដោយសេចក្ដីសង្វេគ ដោយ កិរិយាបាននូវមរណស្សតិ ។

**៧. អារោគ្យមទាទិប្បហានំ** កិរិយាលះបង់នូវសេចក្ដីស្រវឹងដោយ ភាពដែលមិនមានរោគជាដើមបាន ដោយបានឃើញនូវមនុស្សជម្ងឺជាដើមទៅ ក្នុងទីនោះ ។

**៨. ភយភេរវសហនតា** ភាពជាអ្នកអាចអត់ទ្រាំនូវភ័យតូចនិងភ័យ ធំដែលគួរស្បើមបាន ដោយសារក្នុងការជួបប្រទះនឹងអារម្មណ៍ដែលគួរស្ញែង។

**៩. អមនុស្សានំគរុភាវនីយតា** ភាពជាបុគ្គលគួរឱ្យអមនុស្ស ទាំងឡាយគោរពនិងកោតសរសើរ ។

**១០. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** ភាពជាអ្នកមានកិរិយា ប្រព្រឹត្តដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ១០ យ៉ាងនេះ ជាអានិសង្សក្នុងសោសានិកង្គ ដែលភិក្ខុបានរក្សា ហើយដោយល្អ មិនឱ្យធ្លុះធ្លាយ ។

## អានិសង្សក្នុងយថាសន្តិកង្គ មាន ៦ យ៉ាង

**១. ទិទានករណំ** បានឈ្មោះថាធ្វើតាមនូវឱវាទដែលព្រះជិនស្រី ទ្រង់ត្រាស់សំដែងថា "ទីសេនាសនៈណាដែលខ្លួនបានមកហើយ ត្រូវតែត្រេកអរ ដោយទីសេនាសនៈនោះកុំរើរុះ" ដូច្នេះ ។

**២. សព្រហ្មចារីហិតេសិតា** ភាពជាអ្នកស្វែងរកនូវប្រយោជន៍ទុក ឱ្យសព្រហ្មចារីផងគ្នា គឺសំចៃទីសេនាសនៈដទៃទុកឱ្យភិក្ខុឯទៀត ។

**៣. ហីនបណីតវិកប្បបរិច្ចាគោ** កិរិយាលះបង់នូវសេចក្តីកំណត់ ថា ថោកថយនិងថ្កើងថ្កានបាន ។

**៤. អនុរោធវិរោធប្បហានំ** កិរិយាប្រហារបង់នូវសេចក្តីត្រេកអរ និងសេចក្តីពិរោធបាន ។

**៥. អត្រិច្ឆតាយទ្វារបិទហនំ** កិរិយាបិទនូវទ្វារនៃសេចក្តីប្រាថ្នា កន្លង ។ ( សេចក្តីប្រាថ្នារំលងហួសវត្ថុដែលខ្លួនបានរួចហើយ គឺថាបាន ១ ហើយ ប្រាថ្នាចង់បាន ១ ទៀត) ។

**៦. អប្បិច្ឆតានិនំ អនុលោមវុត្តិតា** ភាពជាអ្នកមានកិរិយា ប្រព្រឹត្តដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

ទាំង ៦ យ៉ាងនេះ ជាអានិសង្សក្នុងយថាសន្ថតិកង្គ ដែលភិក្ខុបានរក្សា ហើយដោយល្អ មិនឱ្យបែកធ្លាយ ។

ឲ្យ&ឲ

# អានិសង្សក្នុងនេសជ្ជិកង្គ មាន ៥ យ៉ាង

**១. ចេតសោខនិពន្ធស្សុបច្ឆេទនំ** កិរិយាចូលទៅផ្តាច់បង់នូវកំនួចរបស់ចិត្តដែលធ្លាប់ដេកជាសុខជាដើម ។

**២. សព្វកម្មដ្ឋានានុយោគសប្បាយតា** ភាពនៃឥរិយាបថជាទីសប្បាយដល់កិរិយាប្រកបព្យាយាមក្នុងកម្មដ្ឋានទាំងពួង ។ (វិធីចំរើនគ្រប់កម្មដ្ឋានទាំងអស់ សុទ្ធតែប្រើឥរិយាបថអង្គុយកាលបើរក្សានូវធុតង្គនេះងាយនឹងចំរើនបានតាមសប្បាយព្រោះប្រើឥរិយាបថស្របគ្នា)

**៣. បាសាទិកឥរិយាបថតា** ភាពជាអ្នកមានឥរិយាបថជាទីនាំមកនូវសេចក្តីជ្រះថ្លាដល់ប្រជុំជន ។

**៤. វីរិយារម្ភានុកូលតា** ភាពដ៏សមគួរដល់បុគ្គលជាអ្នកប្រារព្ធនូវសេចក្តីព្យាយាម ។

**៥. សម្មាបដិបត្តិយាសម្ពុព្រូហនំ** កិរិយាបង្កើននូវសម្មាបដិបត្តិ។

ទាំង ៥ យ៉ាងនេះ ជាអានិសង្សក្នុងនេសជ្ជិកង្គ ដែលបុគ្គលរក្សាហើយដោយល្អ មិនឱ្យបែកធ្លាយ ។

ចប់អានិសង្សក្នុង ធុតង្គកថា

**❋**

## អានិសង្សបញ្ញា ៤ យ៉ាង គឺ:

១- កំចាត់បង់នូវកិលេស.

២- សោយរសអរិយផលទាំង ៤.

៣- អាចចូលនិរោធសមាបត្តិ.

៤- អាចលើកខ្លួនឱ្យឡើងដល់ថ្នាក់ ។

## អានិសង្សបញ្ញា ជាបុគ្គលាធិដ្ឋាន

♦♦♦♦♦♦♦♦♦♦♦

# រឿងនាងកុណ្ឌលកេសី

(បញ្ញាដែលខំសាងមក មិនមែនទុកស្ងៀមទេ គឺទុកការពារខ្លួន)

ក្នុងពុទ្ធប្បាទនេះ នាក្រុងរាជគ្រឹះ មានធីតាសេដ្ឋីម្នាក់អាយុ ១៦ ឆ្នាំ មានសម្ផស្សល្អស្រស់គួរជាទីពិចពិលរមិលមើលជាពន់ពេក ។ ជាធម្មតានៃនារីទាំងឡាយដែលស្ថិតនៅក្នុងវ័យអាយុ ១៦ ឆ្នាំ នេះច្រើនតែជាប់ជំពាក់ប្រតិព័ទ្ធចំពោះបុរសជាអចិន្ត្រៃយ៍ ។

ឯមាតាបិតាបានរៀបចំទីកន្លែងឱ្យនាងនៅក្នុងបន្ទប់ដ៏មានសិរីនាប្រាសាទមានជាន់ ៧ ហើយចាត់ឱ្យស្ត្រីជាទាសីម្នាក់ឱ្យនៅបំរើព្រឹកល្ងាច ។ និយាយពីរាជបុរសចាប់បានចោរម្នាក់ចងស្លាបសេក ហើយវាយបណ្តើរទៅទីសម្លាប់ ។ ធីតាសេដ្ឋីឮសម្លេងគឹកកងក៏គិតថា មានហេតុអ្វីនេះ? ទើបចេញមក ឈរមើលប្រុសនោះ ក៏មានចិត្តប្រតិព័ទ្ធស្នេហាប្រាថ្នាចង់បានធ្វើជាស្វាមី ហើយមិនបរិភោគ

អាហារ ដេកសន្ទឹងសន្ធៃលែងនិយាយស្ដីនឹងពីណាសោះ ។

ពេលនោះម្ដាយមកសួរថា នាងមានរោគយ៉ាងណា? លោកម្ដាយបើខ្ញុំបានប្រុសដែលរាជបុរសបណ្ដើរនោះមកធ្វើជាស្វាមី ទើបមានជីវិតរស់នៅ. បើរៃរជាមិនបានវិញ. ជីវិតខ្ញុំពិតជាគ្មានបានរស់នៅតទៅទៀតឡើយ ។ ខ្ញុំនឹងស្លាប់ក្នុងទីនោះឯង ។

ហៃកូនសម្លាញ់ទ្រូងម្ដាយ នាងកុំធ្វើយ៉ាងនេះចាំម្ដាយរកស្វាមីដែលមានជាតិនិងទ្រព្យស្មើគ្នាឱ្យ ។ លោកម្ដាយខ្ញុំឥតត្រូវការប្រុសដទៃទេ បើមិនបានប្រុសនេះជាប្ដីមុខជាស្លាប់ ។ មាតាខំនិយាយលួងលោមយ៉ាងម៉េចក៏នាងកញ្ញាស្ដាប់មិនបាន. ទើបទៅនិយាយរឿងនោះប្រាប់ដល់ស្វាមី ។ បុរសជាបិតាមកនិយាយនៅតែឥតបានការដូចគ្នា ក៏គិតថា អញនឹងធ្វើឧបាយកលយ៉ាងណា? ក៏គិតមិនឆ្ងាយ ក៏ដាច់ចិត្តឱ្យទ្រព្យ ១ ពាន់កហាបណៈ ជាសំណូកដល់រាជបុរសដោយពាក្យថា: ចូរអ្នកទទួលយកទ្រព្យ ហើយឱ្យបុរសជាប់ឃុំនោះមកខ្ញុំ ។

អំណាចសំណូកអាចបង្វែងចិត្តរាជបុរសឱ្យលែងចោរនោះ ហើយចាប់បុរសដទៃមកសម្លាប់ យកដំណឹងនោះទៅទូលព្រះរាជាថា ចោរខ្លួនបានសម្លាប់រួចហើយ ។

ថ្លែងពីសេដ្ឋី កាលបើរាជបុរសឱ្យចោរនោះមកហើយ ក៏នាំយកទៅឱ្យធីតាខ្លួន ។ នាងក្រមុំបានតាក់តែងខ្លួនប្រាណលាបលាបលទប្រេងម្សៅប្រស់ព្រំរាងកាយយ៉ាងស្អាតបាត ដើម្បីឱ្យចោរស្រឡាញ់ ហើយចាត់ចែងវត្ថុទាំងឡាយ មានបបរបាយជាដើមដោយខ្លួនឯង ឱ្យចោរជាស្វាមីបរិភោគ ។ ចោរនោះ បានរួម

រសមេត្រីគ្រេបជញ្ជក់យកលំអងផ្កាដែលមានរសជាតិកំពុងតែរីកថ្មីៗ មានក្លិនពិដោរក្រអូបឈ្ងុយឈ្ងប់បានពីរបីថ្ងៃក៏កើតចិត្តលាមកថា អញធ្វើម្ដេចហ្ន៎ នឹងបានសម្លាប់ស្ត្រីនេះហើយដោះយកគ្រឿងប្រដាប់លក់ទិញស្រាផឹកបាន ? ចុះកើតគំនិតយ៉ាងនេះហើយ ក៏ដេកអត់បាយក្រហាយទឹកមិនស្តីនិយាយរកអ្នកណាសោះ ។ ឯប្រពន្ធ ឃើញដូច្នោះចូលទៅលួងលោមសួរថា បពិត្រស្វាមី បងកើតរោគអ្វី? ឥតមានកើតរោគអ្វីទេអូន ។ ចុះមាតាបិតាខ្ញុំនឹងខឹងចំពោះអ្នកបងឬ? លោកឥតខឹងទេ ។ នាងខំឈ្លេចសួរទៀតថា ចុះបងមានហេតុយ៉ាងណាសូមប្រាប់ឱ្យប្អូនដឹងផង? ប្អូនមាសព្រលឹង កាលរាជបុរសបណ្ដើរបងយកទៅសម្លាប់ បងបានបន់ស្រន់ទេព្តាដែលនៅអាស្រ័យនាជ្រោះសម្រាប់សម្លាប់ចោរថា បើបងបានរួចរស់ជីវិត នឹងធ្វើពលិកម្មថ្វាយ. ឥឡូវនេះបងបានរួចរស់ជីវិតដោយអានុភាពនៃទេព្តានោះឯងដូច្នេះ បងត្រូវតែធ្វើពលិកម្មដល់ទេព្តានោះ ។ បងកុំព្រួយឱ្យសោះ យើងនឹងធ្វើពលិកម្មដើម្បីលាបំណន់. បងប្រាប់មកចុះ តើត្រូវការអ្វីខ្លះ ? ត្រូវការមធុបាយាសមានទឹកតិច ១ ផ្កានានាមានលាជជាគំរប់ ៥ មួយ ។ នាងពោលថា បពិត្រស្វាមី ! ប្រសើរហើយ ខ្ញុំនឹងចាត់ចែងឱ្យបាន. លុះរៀបរួចហើយក៏ប្រាប់ថា បងមកយើងទៅថ្វាយពលិកម្ម ។ ចោរស្វាមីតបថា បើដូច្នោះអូនត្រឡប់វិញចុះ ហើយកាន់យកគ្រឿងអលង្ការវត្ថាភរណ៍[១] មានតម្លៃច្រើន នឹងរៀបចំខ្លួនឱ្យស្អាតបាតផង យើងនៅសើចលេងយ៉ាងសែនសុខ ។

កុណ្ឌលកេសីនាងចេះតែធ្វើតាមព្រោះនាងជាស្ត្រីមានចិត្តស្រឡាញ់ស្មោះ

---

១-គ្រឿងសំលៀកបំពាក់ មានសំពត់អាវជាដើម ។

នឹងស្វាមីចោរនោះណាស់ ។

កាលចោរនាំនាងនោះទៅដល់ជើងភ្នំ ក៏ពោលប្រាប់ថា ប្អូនយើងទាំងពីរនាក់នឹងទៅខាងនាយពីទីនោះ ចូរនាងឱ្យជនបរយានត្រឡប់ទៅវិញ ហើយទទួលភាជនៈដែលដាក់ពលិកម្មខ្លួនឯង យកឡើងទៅលើជ្រោះភ្នំ ។ កាលបុរសស្វាមីនាំនាងទៅលើកំពូលភ្នំហើយ នាងពោលថា បពិត្រស្វាមី ! ចូរអ្នកធ្វើពលិកម្មដល់ទេវតាតាមចិត្តអ្នកប្រាថ្នាចុះ ។ ចោរឈរធ្មឹង ទើបភរិយាសួរថា ហេតុអ្វីបានជាអ្នកទ្រឹងយ៉ាងនេះ ? ក៏ពោលប្រាប់ថា ឥតមានត្រូវការដោយពលិកម្មអ្វីទេ. ដែលអញនាំហងមកនេះ គឺបញ្ឆោតហងទេតើ ។ បពិត្រស្វាមី! អ្នកបញ្ឆោតខ្ញុំប្រាថ្នាយករបស់អ្វី? ប្រាថ្នាសម្លាប់ហងឯងហើយដោះយកគ្រឿងអាភរណៈរត់ទៅ ។ កុណ្ឌលកេសីនាងខ្លាចសេចក្តីស្លាប់ក៏ពោលអង្វរថា ខ្លួនខ្ញុំក្តី គ្រឿងអាភរណៈក្តី សុទ្ធតែរបស់អ្នកហើយតើ ម្តេចក៏អ្នកពោលយ៉ាងនេះ ? ទោះនាងអង្វរថា កុំធ្វើយ៉ាងនេះក៏ចោរនៅតែពោលថា ពិតជាសម្លាប់ហងឯងហើយកុំអង្វរធ្វើអ្វីឥតអំពើទេ ។ នាងប្រាប់ថាបើពិតជាយ៉ាងនេះមែនអ្នកសម្លាប់ខ្ញុំធ្វើអ្វី ? គួរតែយកអាភរណៈទាំងនេះទៅហើយទុកជីវិតឱ្យខ្ញុំ. ចាប់ពីថ្ងៃនេះទៅខ្ញុំថ្វាយខ្លួនទៅជាទាសីធ្វើហត្ថកម្មបំរើអ្នកទាំងអស់ ។

ទើបពោលថា:

**ឥមេ សុវណ្ណកេយូរា សព្វេ វេឡុរិយាមយា**

**សព្វញ្ច គណ្ហ គច្ឆន្តេ មម ទាសិញ្ច សាវយ ឱ**

ខ្សែសយជាវិការៈនៃមាសនេះ សម្រេចពីកែវពិទូរ្យទាំងអស់. អ្នកដឹ

ចំរើនយករបស់ទាំងនេះផង ឱ្យអ្នកស្រុកដឹងឮថា ខ្ញុំជាទាសីអ្នកផង ។

ចោរប្រកែកថា បើអញធ្វើយ៉ាងនេះ ហងនឹងទៅប្រាប់ម្ដាយឪពុកហង មិនខាន. អញពិតជាសម្លាប់ហើយហងកុំយំសោកខ្លាំងពេក. ហើយពោលគាថាថា:

**មា ពាឡ្ហំ បរិទេវេសិ ខិប្បំ ពន្ធាហិ ភណ្ឌកំ**
**ន តុយ្ហំ ជីវិតំ អត្ថិ សព្វំ គណ្ហាមិ ភណ្ឌកំ ខ**

ហងកុំយំខ្លាំងពេក. ចូរស្រាយបង្វិចទ្រព្យឱ្យឆាប់. ជីវិតហងគ្មានទេ អ្នកនឹងយករបស់ទាំងអស់ ។

នាងកុណ្ឌលកេសីគិតថា ឱ ! កម្មនេះធ្ងន់ណាស់ហ្ន៎ ធម្មតាបញ្ញាដែលបុគ្គលសាងសន្សំមកហើយ មិនមែនទុកស្ងោរស៊ីទេ គឺទុកដើម្បីពិចារណាការពារភយន្តរាយ. ត្រូវអញល្បងបញ្ញាសាកនឹងគាត់នេះលមើល ! ទើបពោលអង្វរថា កាលដែលរាជបុរសចាប់បងចោទថាចោរហើយនាំទៅសម្លាប់ ខ្ញុំបានប្រាប់មាតា-បិតាខ្ញុំឱ្យ១ ប្រាក់ ១ ពាន់កហាបណៈទៅលោះបងនាំយកមកផ្ទះ. ខ្ញុំជាអ្នកមានឧបការៈតាំងពីពេលនោះមក ថ្ងៃនេះគួរបងធ្វើខ្លួនឱ្យប្រពៃ ខ្ញុំនឹងថ្វាយបង្គំលាស្លាប់ឥឡូវហើយ ។

ចោរអរណាស់ពោលថា ល្អហើយ ល្អហើយ ទើបឈរបែរមុខទៅជ្រោះភ្នំឱ្យនាងថ្វាយបង្គំ ។ នាងដើរប្រទក្សិណបុរសនោះបីជុំទើបថ្វាយបង្គំទិសទាំង ៤ ពោលរៀបរាប់ថា បពិត្រស្វាមី ការឃើញរូបលោកបងក៏រលត់ត្រឹមថ្ងៃនេះ លោកបងក៏ខានឃើញរូបខ្ញុំថ្ងៃនេះដែរ. ហើយនាងធ្វើអាការៈឱបរិត១ ហាក់

ដូចជាមានអាល័យចំពោះរូបចោរជាស្វាមីពន់ពេក. បានឱកាសឈរពីក្រោយខ្នងចោរដែលកំពុងធ្វេសប្រហែសហើយ ក៏យកដៃម្ខាងចាប់ក ដៃម្ខាងទៀតចាប់ស្ទាបប្រជៀវចោរនោះ ហើយច្រានទំលាក់ទៅក្នុងជ្រោះភ្នំទៅ ។ ចោរធ្លាក់ចុះមកបះទង្គិចនឹងចង្កេះភ្នំដាច់ដោចខ្លួនប្រាណកំណាត់ៗ ទើបធ្លាក់មកដល់ដីក្សិណក្ស័យក្នុងពេលនោះឯង ។

ទេព្តាដែលអាស្រ័យលើភ្នំនោះ ក៏ឱ្យពរសាធុការដល់នាងកុណ្ឌលកេសីគ្រប់គ្នា ដោយឧទានគាថា ថា:

**ន សោ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ**
**ឥត្ថីបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា ។**

បុរសនោះមិនមែនមានប្រាជ្ញាសព្វទីឋានទេ ឯស្ត្រីជាបណ្ឌិតមានបញ្ញាសម្រាប់ពិចារណា រមែងមានក្នុងទីនោះ ៗ ។

និពន្ធបណ្ឌិត

**យិន_វន់**

ជំហ៊ានទី ១០

✳✳❋✳✳